


# ការប្រឈមរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យឆ្នាំ ២០១៧

cambodian center for independent media

FUNDED BY
សហភាពអឺរ៉ុប

Published by the Cambodian Center for Independent Media (CCIM) with the generous support of the European Union

The European Commission support for the production of this publication does not constitute an endorsement of the contents which reflects the view only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

FOR MORE INFORMATION:
House No. 14A, St. 392, Sangkat Beoung Keng Kang I,
Khan Chamkarmon, Phnom Penh, Kingdom of Cambodia
www.ccimcambodia.org
communications@ccimcambodia.org
+855 (0)23 726 842

Challenges for Independent Media 2017

# តារាងមាតិកា


សេចក្តីសង្ខេប 2

វិធីសាស្រ្ត 4

ប្រជាសាស្រ្តស្ទង់មតិ 4

ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ 6

អ៊ីនធឺណិត 6

ទូរទស្សន៍ 8

វិទ្យុ 8

កាសែតបោះពុម្ព 8

សមាគមអ្នកសារព័ត៌មាន 9

ចំណាត់ថ្នាក់ 9

ការប្រឈមសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ 10

ការគំរាមកំហែង និងការចាប់ដាក់ពន្ធនាគារគឺជារឿងធម្មតាឬ? 10

"ការបង្ក្រាប" 12

ការបន្តចាប់ខ្លួន 13

ភាពស្ងៀមស្ងាត់ និងវិបត្តិផ្លូវចិត្ត 14

ការមិនអាចប៉ះពាល់បាន 16

ការកើនឡើងឆាប់រហ័សនៃប្រព័ន្ធឌីជីថល 18

ការចាប់ខ្លួនពាក់ព័ន្ធការបញ្ចេញមតិតាមទំព័រហ្វេសប៊ុក 18

កាន់តែមានការបណ្តុះបណ្តាល កាន់តែមានការត្រួតពិនិត្យតាមដាន 20

កង្វះវិជ្ជាជីវៈ 22

អ្នកគំរាមទារប្រាក់ 22

ការទទួលបានព័ត៌មាន 24

លក្ខខណ្ឌការងារ 24

យេនឌ័រ 24

អនុសាសន៍ 26

# សេចក្ដីសង្ខេប

"យើងព្រួយបារម្ភណាស់។ យើងត្រូវតែប្រុងប្រយ័ត្ន។ ឥឡូវនេះមិនមានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យច្រើនទៀតទេ។ នៅពេលដែលនៅឯកោយើងពិតជាពិបាកមែន។ អនាគតគឺមិនច្បាស់លាស់ទេ"

### លទ្ធផលរកឃើញសំខាន់ៗ

មានអ្នកសារព័ត៌មានត្រឹមតែ១១%ប៉ុណ្ណោះនិយាយថា ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាដើរតាមទិសដៅត្រូវ ពោលគឺថយចុះពី៧១%ក្នុងឆ្នាំ២០១៥

មានអ្នកសារព័ត៌មាន ៨៣% និយាយថា សេរីភាពប្រព័ន្ធផ្សព្វផ្សាយបានធ្លាក់ចុះកាលពីឆ្នាំកន្លងមក

មានអ្នកសារព័ត៌មាន៩២%ចាត់ទុកការបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅឆ្នាំនេះថាជារឿងនយោបាយ

មានអ្នកសារព័ត៌មាន៣៨%និយាយថា ពួកគេទទួលរងការវាយប្រហារដោយពាក្យសម្ដី ឬការយាយីផ្នែករាងកាយក្នុងពេលបំពេញការងារនៅកម្ពុជា ហើយ ៤៧% និយាយថាពួកគេទទួលរងការគំរាមកំហែងក្នុងរយៈពេលកន្លងមក

មានអ្នកសារព័ត៌មាន១៤%បាននិយាយថា ពួកគេបានទទួលរងការវាយប្រហារកាលពីឆ្នាំកន្លងទៅ ហើយ ២០% ទៀតនិយាយថាពួកគេបានទទួលរងការគំរាមកំហែង

មានអ្នកសារព័ត៌មាន ៦៧% និយាយថាពួកគេមានអារម្មណ៍ថា ពួកគេមិនមានសេរីភាពពេញលេញក្នុងការ

រូបភាពនៃសេរីភាពប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសកម្ពុជាបានដួលរលំក្នុងឆ្នាំ២០១៧។ អាជ្ញាធរបានបិទស្ថានីយវិទ្យុចំនួន៣២ប៉ុស្តិ៍ដែលផ្សាយព័ត៌មានបក្សប្រឆាំង ព័ត៌មានដែលផ្ដល់មូលនិធិដោយសហរដ្ឋអាមេរិក ឬផ្សាយព័ត៌មានឯករាជ្យ។ រដ្ឋាភិបាលវាយប្រហារទៅលើប្រព័ន្ធផ្សព្វផ្សាយដែលតែងតែរិះគន់ខ្លាំងៗដោយប្រើប្រាស់ការស៊ើបអង្កេតលើការបង់ពន្ធហើយបានបិទសារព័ត៌មាននោះ ព្រមទាំងគំរាមកំហែង និងចាប់អ្នកកាសែតពីបទ"ញុះញង់"និង"ការផ្ដល់ជូនឲ្យរដ្ឋបរទេសនូវព័ត៌មានដែលបង្កភាពអន្តរាយដល់សន្តិសុខជាតិ"ដោយប្រើវោហាសាស្ត្រធ្ងន់ៗអះអាងថាមានភ្នាក់ងារបរទេសបានកំពុងតែប៉ុនប៉ងផ្ដួលរំលំរដ្ឋាភិបាល។

ជាវិស័យមួយដែលធ្លាប់តែផ្ដល់នូវរូបភាពនៃលទ្ធិប្រជាធិបតេយ្យ ដោយមានប្រព័ន្ធព័ត៌មានដែលផ្សព្វផ្សាយព័ត៌មានរិះគន់ដោយសេរីក្នុងខណៈដែលមានទូរទស្សន៍ និងកាសែតគាំទ្របក្សកាន់អំណាចជាច្រើនដែរនោះ  ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជានាពេលបច្ចុប្បន្ននេះត្រូវកាត់បន្ថយ និងត្រូវប៉ះពាល់យ៉ាងខ្លាំង។ អ្នកសារព័ត៌មាននិយាយថា ពួកគេធ្វើការដោយដឹងច្បាស់ថា ពួកគេអាចក្លាយជាមុខសញ្ញាបន្ទាប់ទៀតដោយសារតែការងាររបស់ខ្លួន។ ពួកគេនិយាយថា ឥឡូវនេះប្រភពព័ត៌មានទាំងឡាយស្ទាក់ស្ទើរមិនហ៊ានផ្ដល់ព័ត៌មាននោះទេ ចំណែកឯអាជ្ញាធរមូលដ្ឋានក៏បង្កើនការគំរាមកំហែងដល់អ្នកសារព័ត៌មានទាំងនោះដែរ។

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះអ្នកសារព័ត៌មានដែលបានបង្ហាញក្ដីសង្ឃឹមរបស់ពួកគេថា ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាបានដើរលើផ្លូវត្រូវនោះ បែរជាត្រូវខកបំណងទៅវិញ។ មានអ្នកសារព័ត៌មានត្រឹមតែ ១១% ប៉ុណ្ណោះដែលស្ទង់មតិនៅឆ្នាំនេះបាននិយាយថា ប្រព័ន្ធផ្សព្វផ្សាយបានដើរលើផ្លូវត្រូវ។ ដោយឡែកអ្នកសារព័ត៌មាន ៨៣%  ផ្សេងទៀតលើកឡើងថា សេរីភាពរបស់ប្រព័ន្ធផ្សព្វផ្សាយបានធ្លាក់ចុះក្នុងឆ្នាំកន្លងមកនេះ។ អ្នកសារព័ត៌មានជាច្រើននិយាយថា បញ្ហានេះបានកើតឡើងយ៉ាងជាក់ស្ដែង។

បើក្រឡេកទៅអនាគតវិញ អ្នកសារព័ត៌មានមិនប្រាកដទេថា តើភាពច្របូកច្របល់នៅឆ្នាំនេះដែលមានអ្នកសារព័ត៌មានរហូតដល់ ៩២% ចាត់ទុកថាជាការបង្ក្រាបទៅលើប្រព័ន្ធផ្សព្វផ្សាយដោយសាររឿងនយោបាយនោះ នឹងទំនងជាអាចកើតឡើងបន្តទៀតឬយ៉ាងណានោះទេ។ អ្នកសារព័ត៌មានខ្លះគិតថាបញ្ហានោះបានបញ្ចប់រួចទៅហើយ។ ពួកគេនិយាយថា ក្រោយពីការរំលាយគណបក្សប្រឆាំងក្នុងខែវិច្ឆិកាមក គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចទទួលបានការគ្រប់គ្រងដោយឯកបក្សដោយមិនចាំបាច់ដាក់គំនាបអ្វីបន្តទៀតទេ។

ដោយឡែក មានការរីកដុះដាលនូវប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឌីជីថលបាននាំឲ្យមានទាំងក្ដីសង្ឃឹមផង ទាំងក្ដីបារម្ភ ផង។ ខណៈពេលដែលពលរដ្ឋខ្មែរភាគច្រើនបាន និងកំពុងបន្តចែករំលែកព័ត៌មាន និងមតិយោបល់តាមបណ្ដាយសង្គមហ្វេសប៊ុកនោះ អាជ្ញាធរបានចាប់ខ្លួន ឬស្វែងរកចាប់ខ្លួនមនុស្សយ៉ាងហោចណាស់ ៧ នាក់នៅឆ្នាំនេះផងដែរ ដែលការណ៍នេះត្រូវបានគេចាត់ទុកថាប្រព្រឹត្តជ្រុលហួសហេតុ។ អ្នកសារព័ត៌មានដែលបានចូលរួមក្នុងការស្ទង់មតិមានយោបល់ផ្ទុយគ្នាទៅលើបញ្ហាថា តើការកើនឡើងនូវប្រភពព័ត៌មានតាមអនឡាញបានជួយផ្តល់សេរីភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាឬយ៉ាងណា ។ នៅពេលដែលព័ត៌មានបានដឹងឮយ៉ាងឆាប់រហ័សក្នុងមួយថ្ងៃៗនោះ ក៏មានការបែកធ្លាយព័ត៌មាន និងរបាយការណ៍ដែលគ្មានការបញ្ជាក់ប្រភពច្បាស់លាស់ដ៏ច្រើនដែលប្រកួតប្រជែងជាមួយការរាយការណ៍ព័ត៌មានបែបប្រពៃណីដែរផងដែរ។

ទោះជាយ៉ាងនេះក្តី ចំពោះអ្នកសារព័ត៌មានជាច្រើននៅក្នុងប្រទេសនេះ អ្វីៗដំណើរការទៅដូចធម្មតាដដែល។ ជាមធ្យម ពួកគេពេញចិត្តល្មមៗនឹងការងាររបស់គេ (ដោយមានអត្រា៣,៤ក្នុងចំណោម៥) ហើយកំពុងទទួលការបណ្តុះបណ្តាលជារឿយៗ រួមមានពីក្រសួងព័ត៌មាននិងសមាគមអ្នកសារព័ត៌មាននានាដែលមានទំនាក់ទំនងនឹងគណបក្សកាន់អំណាច។ នៅតាមការិយាល័យកាសែត និងស្ថានីយទូរទស្សន៍ដែលលម្អៀងទៅរករដ្ឋាភិបាល អ្នកសារព័ត៌មានគ្រាន់តែនិយាយថា ពួកគេនឹងបន្តសរសេរអត្ថបទទាំងឡាយដែលប្រធានរបស់ពួកគេទាមទារឲ្យសរសេរតែប៉ុណ្ណោះ ពោលគឺជាការសរសេរដែលបង្ហាញពីវឌ្ឍនភាពនិងកិច្ចអភិវឌ្ឍវិជ្ជមានរបស់កម្ពុជា។

រាយការណ៍ព័ត៌មានគ្រប់ប្រធានបទ ដោយគ្មានភាពភ័យខ្លាចចំពោះការជ្រៀតជ្រែក ឬផលប៉ះពាល់នោះឡើយ ពោលគឺនិន្នាការនេះមានការកើនឡើងពី ៥៨% ក្នុងឆ្នាំ២០១៥ និង ៤៧% ក្នុងឆ្នាំ២០១៤

មានអ្នកសារព័ត៌មាន៩១%ឥឡូវនេះប្រើសេវាបញ្ជូនសារដោយមានលេខកូដសម្ងាត់ WhatsApp សម្រាប់ទាក់ទងគ្នាក្នុងការងារ

អំពើពុករលួយត្រូវបានចាត់ថ្នាក់ជាប្រធានបទដ៏ពិបាកបំផុតក្នុងការរាយការណ៍នៅកម្ពុជា ដោយមានពិន្ទុមធ្យម ៤,២ក្នុងចំណោម៥ពិន្ទុ

មានអ្នកសារព័ត៌មាន៦០%និយាយថា ពួកគេបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលច្រើនជាង៥ដងក្នុងពេលបម្រើការងារនៅកម្ពុជា

មានអ្នកសារព័ត៌មាន៨៥%និយាយថា ពួកគេមិនគិតថាមានអ្នកសារព័ត៌មានភាគច្រើនមានវិជ្ជាជីវៈគ្រប់គ្រាន់នោះឡើយ

កាសែត ឌឹខេមបូឌា ដេលី កាសែត ភ្នំពេញប៉ុស្តិ៍ និងវិទ្យុវីអូអេ មានចំណាត់ថ្នាក់ជាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបំផុតនៅប្រទេសកម្ពុជានាឆ្នាំ២០១៧

បណ្តាញព័ត៌មាន Fresh News ទូរទស្សន៍ Nice TV និងបាយ័នមានចំណាត់ថ្នាក់ជាប្រព័ន្ធផ្សព្វផ្សាយដែលមានឯករាជ្យតិចបំផុត

# វិធីសាស្ត្រ

អ្នកយកព័ត៌មាន អ្នកថតរូប និពន្ធនាយក ផលិតករ អ្នកអប់រំ និងចាងហ្វាងការផ្សាយចំនួន៧៥នាក់ដែលធ្វើការនៅកម្ពុជាបានចូលរួមក្នុងការផ្តល់ទស្សនៈយល់ឃើញរបស់ខ្លួនទាក់ទងនឹងវិស័យប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសនេះ។ ពួកគេបាននិយាយអំពីស្ថានភាពការងារ ការជួបញ្ហាលំបាកក្នុងការទទួលបានព័ត៌មាន ការអភិវឌ្ឍផ្នែកឌីជីថល ក្រមសីលធម៌អ្នកសារព័ត៌មាន និងការគំរាមកំហែង ព្រមទាំងការវាយប្រហារដែលពួកគេប្រឈមមុខ។

ការស្ទង់មតិបានធ្វើឡើងតាមគំរូដែលចាប់ផ្តើមដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងឆ្នាំ២០១៤ ក្នុងនោះមានអ្នកសារព័ត៌មានចំនួន៧៨នាក់ត្រូវបានសម្ភាសដោយផ្ទាល់។ ឆ្នាំបន្ទាប់មកទៀត គឺមានអ្នកសារព័ត៌មានចំនួន១០២នាក់ត្រូវស្ទង់មតិផ្ទាល់តាមទូរស័ព្ទ និងតាមអនឡាញ។ របាយការណ៍ឆ្នាំ២០១៦បានពន្យារពេលរហូតដល់ដើមឆ្នាំនេះ ដែលនៅពេលនោះមានការស្ទង់មតិខ្លីមួយសម្រាប់អ្នកមានវិជ្ជាជីវៈផ្នែកសារព័ត៌មានចំនួន២២នាក់។

ការស្ទង់មតិឆ្នាំ២០១៧បានធ្វើឡើងក្នុងខែវិច្ឆិកា ហើយត្រូវសម្ភាសន៍អ្នកធ្វើការនៅក្រុងភ្នំពេញដោយផ្ទាល់ និងសម្ភាសន៍អ្នកធ្វើការនៅតាមខេត្ត (១៧%) តាមទូរស័ព្ទ។ អត្តសញ្ញាណរបស់អ្នកចូលរួមក្នុងការស្ទង់មតិត្រូវបានរក្សាទុកដោយសម្ងាត់ ដើម្បីឲ្យអ្នកផ្តល់បទសម្ភាសន៍ហ៊ានបញ្ចេញមតិដោយសេរីទាក់ទងនឹងកន្លែងធ្វើការរបស់ពួកគេ និងអំពីការគំរាមកំហែងដែលគេជួបប្រទះ។ ចម្លើយរបស់ពួកគេត្រូវវិភាគតាមវិធីសាស្ត្របរិមាណវិស័យនិងបែបគុណវិស័យដូចខាងក្រោមនេះ។

## ប្រជាសាស្ត្រស្ទង់មតិ

### យេនឌ័រ



ស្ត្រី 36% បុរស 64%

### អាយុ




### បទពិសោធន៍គិតជាឆ្នាំ




### សញ្ជាតិ



កម្ពុជា 76% បរទេស 24%

ទីតាំង




មុខតំណែង




ប្រភេទនៃអង្គភាពសារព័ត៌មាន




ចំនួននៃអង្គភាពសារព័ត៌មានបោះពុម្ព

41

## ការកម្រិត

ការស្ទង់មតិនេះមានគោលបំណងទាញយកការបញ្ចេញមតិច្រើន ដែលមានទាំងបុរស និងស្ត្រី ពោលគឺអ្នកធ្វើការឲ្យប្រព័ន្ធផ្សព្វផ្សាយលម្អៀងទៅរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយជាកម្មសិទ្ធិរបស់បរទេស មានវ័យចម្រុះ មានកម្រិតនៃបទពិសោធន៍ និងមុខតំណែងផ្សេងៗគ្នា ប៉ុន្តែវាមិនមែនជាប៉ាន់គំរូដោយចៃដន្យនោះទេ។ ឧទាហរណ៍ មានអ្នកឆ្លើយចំនួន៥០%ដែលបង្ហាញទស្សនៈមួយចំនួន តែមិនអាចតាងឲ្យអ្វីដែលអ្នកសារព័ត៌មាន៥០%ក្នុងបណ្តាអ្នកសារព័ត៌មានទាំងអស់នៅកម្ពុជានឹងបញ្ចេញយោបល់នោះឡើយ។ ការបកស្រាយលទ្ធផលនឹងមានភាពគាប់ប្រសើរទៅបាន គឺទាល់តែផ្អែកទៅតាមសម្តីអ្នកសារព័ត៌មានមួយចំនួនធំនៅក្នុងប្រទេសនេះបាននិយាយប៉ុណ្ណោះ ពោលគឺមិនបានធ្វើសេចក្តីសន្និដ្ឋានបន្ថែមទៀតឡើយ។

ការស្ទង់មតិនេះក៏បានធ្វើឡើងក្នុងពេលដែលមានព្រឹត្តការណ៍វិវត្តន៍ថ្មីៗដ៏សកម្មទាំងផ្នែកនយោបាយទាំងផ្នែកប្រព័ន្ធផ្សព្វផ្សាយដែរ។ អ្នកសារព័ត៌មានខ្លះត្រូវបានសម្ភាសន៍មុននឹងមានការចាប់ខ្លួនអ្នកកាសែតពីរនាក់ ដែលតុលាការចោទប្រកាន់ពីបទប្រគល់ឲ្យរដ្ឋបរទេសនូវព័ត៌មានដែលបង្កអន្តរាយដល់សន្តិសុខជាតិកាលពីថ្ងៃទី១៤ ខែវិច្ឆិកា ហើយនិងការរំលាយគណបក្សប្រឆាំងកាលពីថ្ងៃទី១៦ ខែវិច្ឆិកា។ អ្នកសារព័ត៌មានផ្សេងទៀតត្រូវបានសម្ភាសន៍ក្រោយពីកើតព្រឹត្តិការណ៍ទាំងនោះ។ ប្រហែលជានឹងអាចមានព្រឹត្តិការណ៍វិវត្តបន្តទៀតនៅចន្លោះពេលដែលរបាយការណ៍នេះបានសរសេរឡើង (នៅចុងខែវិច្ឆិកា) និងបំណាច់ឆ្នាំ២០១៧។

# ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយ

> “វាមិនប៉ះពាល់ដល់ពួកយើងទេ។ ខ្ញុំធ្វើការឲ្យស្ថាប័នសារព័ត៌មានខុសៗគ្នា។ អត្ថបទរបស់យើងមានខ្លឹមសារដដែលៗ។ វាគ្រាន់តែប៉ះពាល់ដល់អង្គភាពសារព័ត៌មានណាដែលមិនគាំទ្ររដ្ឋាភិបាលប៉ុណ្ណោះ”

ជាយូរមកហើយដែលទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសនេះ ត្រូវខណ្ឌចែកដាច់ពីគ្នារវាងកាសែតជាភាសាខ្មែរ និងស្ថានីយ៍ទូរទស្សន៍ទាំងឡាយដែលមានទំនាក់ទំនងនឹងគណបក្សកាន់អំណាច ដែលនៅក្នុងការស្ទង់មតិរបស់អ្នកសារព័ត៌មានកាលពីលើកមុនៗចាត់ទុកថាគ្រប់គ្រងយ៉ាងតឹងរ៉ឹង និងមិនអាចជឿទុកចិត្តបាន និងកាសែត វិទ្យុមួយចំនួនតូចភាគច្រើនជាកម្មសិទ្ធិរបស់បរទេសដែលគេមានសេរីភាពក្នុងការពិនិត្យមើលអ្នកកាន់អំណាច។

របៀបរបបចាស់នេះត្រូវបានធ្វើអោយខូចដោយសារតែហេតុផលពីរ ។ ទីមួយ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកំពុងតែទទួលរងការត្រួតពិនិត្យរុះរើនៅឆ្នាំនេះតាមរយៈព្រឹត្តិការណ៍ផ្លាស់ប្តូរភ្លាមៗដ៏ច្រើន ។ ទីពីរ ប្រព័ន្ធផ្សព្វផ្សាយមិនថាជាទូរទស្សន៍ កាសែត ឬវិទ្យុនោះទេ បាននិងកំពុងតែដណ្តើមគ្នាគ្រប់គ្រងអនាគតនៃប្រព័ន្ធឌីជីថល។

## អ៊ីនធឺណិត

អ៊ីនធឺណិតជាប្រភពព័ត៌មានអនឡាញជំនួសឲ្យទូរទស្សន៍។ វាជាបណ្តាញព័ត៌មានពេញនិយមបំផុតក្នុងឆ្នាំ២០១៦ដោយតំណាងអោយរហូតដល់ ៣០% នៃប្រភពព័ត៌មានអនឡាញទាំងអស់ ។ ពិសេសជាងនេះទៀតនោះ បណ្តាញសង្គមហ្វេសប៊ុកគឺជាវេទិកាឌីជីថលដែលពេញនិយមជាងគេនៅកម្ពុជា។ ស្ថានីយទូរទស្សន៍បានចាប់ផ្តើមផ្សាយបន្តផ្ទាល់កម្មវិធីមួយចំនួនរបស់ខ្លួនតាមហ្វេសប៊ុក ចំណែកឯវិទ្យុខ្លះវិញក៏កំពុងសង្ឃឹមថានឹងផ្សាយអត្ថបទរបស់ខ្លួនតាមអនឡាញផងដែរក្រោយពេលត្រូវរារាំងមិនឲ្យផ្សាយតាមរលកធាតុអាកាស។ ពលរដ្ឋខ្មែរ៤៨%និយាយថា ពួកគេយ៉ាងហោចណាស់ក៏មានទូរស័ព្ទទំនើបមួយគ្រឿងដែរ ហើយមានចំនួនពលរដ្ឋដូចគ្នានេះនិយាយថា ពួកគេមានអ៊ិនធឺណិតប្រើប្រាស់។

អ្នកដើរតួដ៏ល្បីល្បាញនិងចម្រូងចម្រាសបំផុតនៅក្នុងលំហឌីជីថលគឺ Fresh News ដែលជាអង្គភាពព័ត៌មានផ្សាយសេចក្តីប្រកាសរបស់រដ្ឋាភិបាល ហើយបានជំរុញឲ្យហួសព្រំដែននៃព័ត៌មាននិងមតិដោយមានផ្សាយអត្ថបទវាយប្រហារ និងការបែកធ្លាយព័ត៌មានផង។ បង្កើតនៅឆ្នាំ២០១២ និងដឹកនាំដោយលោក លឹម ជាវុត្ថា នាយកប្រតិបត្តិវេបសាយនេះ គឺជាបុព្វហេតុចម្បងនៃភាពចម្រូងចម្រាសផ្នែកនយោបាយជាច្រើនដែលបានកើតឡើងថ្មីៗនេះ រួមមានការចោទប្រកាន់ច្រំដែលៗថាមានការឃុបឃិតជាអន្តរជាតិទាក់ទងនឹងគណបក្សប្រឆាំង សហរដ្ឋអាមេរិក និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានព្រមទាំងអង្គការក្រៅរដ្ឋាភិបាលផង។ អ្នកសារព័ត៌មានដែលបានស្ទង់មតិនៅឆ្នាំនេះបានចាត់ទុកស្ថាប័នមួយនេះថាមានឯករាជ្យតិចតួចបំផុតដោយមានពិន្ទុ៤,៨ក្នុងបណ្តា៥ពិន្ទុ។ ទោះជាយ៉ាងនេះក្តី កេរ្តិ៍ឈ្មោះរបស់ស្ថាប័ននេះក៏មិនបានធ្លាក់ចុះទេ ពោលគឺក្រុមហ៊ុនវិភាគវេបសាយ Alexa ចុះបញ្ជី Fresh News ថាជាវេបសាយក្នុងស្រុកដែលគេនិយមមើលច្រើនបំផុតទីបីរបស់ប្រទេសនេះ គឺនៅចំណាត់ថ្នាក់បន្ទាប់ពីវេបសាយកម្សាន្តដូចជា Khmerload និង Sabay។ ប៉ុស្តិ៍ញូវ (មិនទាក់ទងគ្នានឹងកាសែតភ្នំពេញប៉ុស្តិ៍ទេ) និងវេបសាយកាសែតប្រចាំថ្ងៃកោះសន្តិភាព គឺស្ថិតនៅលំដាប់បន្ទាប់។

វិស័យឌីជីថលត្រូវគេចាត់ទុកថាមានសក្តានុពល អាចបំបែកការប្រមូលផ្តុំកម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយនៅក្នុងដៃពាណិជ្ជករមានស្តុកស្តម្ភមួយចំនួនដែលមានទំនាក់ទំនងនឹងរដ្ឋាភិបាល។ យោងតាមគម្រោងពិនិត្យមើលម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ ដែលជាគម្រោង

ស្រាវជ្រាវរួមគ្នាមួយរវាងមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងអ្នកយកព័ត៌មានគ្មានព្រំដែន នៅឆ្នាំ២០១៥ មានវេបសាយព័ត៌មានចំនួន៤ក្នុងចំណោមវេបសាយព័ត៌មានចំនួន១០ដ៏មានប្រជាប្រិយមានការជាប់ទាក់ទងនឹងគណបក្សកាន់អំណាច។

ប៉ុន្តែទោះជាមានម្ចាស់កម្មសិទ្ធិចម្រុះច្រើនក៏ដោយ ក៏អ្នកសារព័ត៌មានទទួលស្គាល់ថាមានការត្រួតពិនិត្យខ្លួនឯងជាមុន កាលណាពាក់ព័ន្ធនឹងរឿងនយោបាយ ជាពិសេសអត្ថបទទាំងឡាយណាដែលរិះគន់រដ្ឋាភិបាល គឺមិនត្រូវសរសេរទេ។ ការចាប់ខ្លួនដោយសារការបង្ហោះសាររិះគន់ខ្លាំងៗតាមហ្វេសប៊ុក និងការគំរាមផ្នែកផ្លូវច្បាប់ប្រឆាំងនឹងអ្នកសារព័ត៌មាន ជាពិសេសអ្នកយកព័ត៌មានមកពីវិទ្យុអាស៊ីសេរីដែលផ្តល់មូលនិធិដោយសហរដ្ឋអាមេរិក ក៏បានបង្កឲ្យមានការភ័យខ្លាចដល់អ្នកសារព័ត៌មានដ៏ទៃផ្សេងទៀតផងដែរ។ សរុបមក មានអ្នកសារព័ត៌មានដែលបានស្ទង់មតិត្រឹមតែ៣៣%ប៉ុណ្ណោះបាននិយាយថា ពួកគេមានសេរីភាពសរសេររាល់ប្រធានបទទាំងឡាយ ដោយគ្មានការជ្រៀតជ្រែក ឬភ័យខ្លាចមានបញ្ហាណាមួយនោះទេ ពោលគឺថយចុះពី៤២% ក្នុងឆ្នាំ២០១៥។

ចំពោះស្ថាប័នសារព័ត៌មានដែលផ្អែកលើវេបសាយសុទ្ធសាធ អ្នកសារព័ត៌មានដែលបានចូលរួមក្នុងការស្ទង់មតិបានចាត់ទុកវេបសាយសារព័ត៌មាន "ថ្មីៗ" ជាវេបសាយមានម្ចាស់កម្មសិទ្ធិឯកជន ។ ចាប់ផ្តើមចេញផ្សាយក្នុងឆ្នាំ២០១២ "ថ្មីៗ" ត្រូវបានបង្កើត និងដឹកនាំដោយលោក ម៉េងលី ចាន់ឌី គួជ អ្នកមានសប្បុរសធម៌ជនជាតិអាមេរិកាំងដើមកំណើតខ្មែរ និងអតីតអ្នកឆ្លើយឆ្លងព័ត៌មានវិទ្យុបារាំងអន្តរជាតិ។ វេបសាយ Sabay ដែលក្នុងរយៈពេលថ្មីៗនេះបានបើកអោយដំណើរការវេបសាយព័ត៌មានមួយទៀតដែលមានឈ្មោះថា "ខ្លីៗ" នោះក៏ត្រូវបានចាត់ទុកថាដែលមានឯករាជ្យភាពគ្រាន់បើដែរ។

ក្រាបហ្វិក- ពិន្ទុឯករាជ្យ




*Severely disrupted in 2017
1 = Always independent and unbiased; 5 = Never independent

## ទូរទស្សន៍

ទូរទស្សន៍នៅតែជាប្រភពព័ត៌មានពេញនិយមបំផុតទីពីរ ហើយល្បីខាងជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍បក្សកាន់អំណាច។ បើយោងតាមគម្រោងពិនិត្យមើលម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ មានស្ថានីយ៍ចំនួន ៨ក្នុងបណ្ដាស្ថានីយ៍ធំៗទាំង១០ គឺជាកម្មសិទ្ធិរបស់អ្នកដែលមានទំនាក់ទំនងជិតស្និតនឹងបក្សកាន់អំណាច រួមមានកូនស្រីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺអ្នកស្រី ហ៊ុន ម៉ាណា លោក កៅ គីមហួន មន្ត្រីជាន់ខ្ពស់នៃការិយាល័យលោកនាយករដ្ឋមន្ត្រី និងលោក គិត ម៉េង ជាឧកញ៉ាដ៏សំខាន់ដែលគេស្គាល់ថាជាប់ទាក់ទងនឹងគណបក្សប្រជាជនកម្ពុជា។

ក្នុងខែកញ្ញា ក្រសួងមហាផ្ទៃក៏បានបើកផ្លូវការនូវទូរទស្សន៍ Nice TV ជាស្ថានីយ៍ទូរទស្សន៍គាំទ្រដោយប្រទេសចិន ដោយបានសន្យាថានឹងផ្សព្វផ្សាយ“ព័ត៌មានសន្តិសុខសង្គម”។ ប៉ុន្តែទូរទស្សន៍នេះផ្សាយអំពីសកម្មភាពអនុវត្តច្បាប់ រួមទាំងការកម្សាន្តផងដែរ។

សរុបមក អ្នកសារព័ត៌មានបានឲ្យចំណាត់ថ្នាក់ស្ថានីយ៍ទូរទស្សន៍ទាំងអស់ថាមានឯករាជ្យតិចតួចបំផុត ពោលគឺជាមធ្យមទទួលបានពិន្ទុ ៤,៥ក្នុងបណ្ដា៥ពិន្ទុ។ ទូរទស្សន៍ Nice TV និងបាយ័ន គឺត្រូវគេចាត់ទុកអាក្រក់បំផុត ដោយទូរទស្សន៍ទាំងពីរមានពិន្ទុ៤,៧ ចំណែកឯទូរទស្សន៍ហង្សមាសវិញមានចំណាត់ថ្នាក់ថាមានឯករាជ្យបំផុត គឺមានពិន្ទុ៤,៣។

## វិទ្យុ

វិទ្យុបានជួបប្រទះនឹងការរារាំងដ៏ធំបំផុតនៅឆ្នាំនេះ ក្នុងពេលដែលមានបរិយាកាសនយោបាយដ៏ក្ដៅគគុក។ ទោះបីមានប្រជាប្រិយភាពធ្លាក់ចុះក៏ដោយ ក៏វិទ្យុនៅតែត្រូវបានគេចាត់ទុកថាសារៈសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានទៅតាមបណ្ដាខេត្តនានា។ នេះជារឿងពិត គឺនៅមុនពេលកម្មវិធីវិទ្យុភាគច្រើនបំផុតដែលរិះគន់រដ្ឋាភិបាលត្រូវគេបិទលែងឲ្យផ្សាយ។

ការផ្សាយរបស់គណបក្សសង្គ្រោះជាតិតាមរយៈស្ថានីយ៍វិទ្យុក្នុងស្រុកត្រូវអាជ្ញាធរបិទចោលពីរបីខែ មុននឹងគណបក្សប្រឆាំងនេះត្រូវគេរំលាយចោលក្នុងខែវិច្ឆិកា។ វិទ្យុអាស៊ីសេរី ដែលផ្ដល់ថវិកាដោយសហរដ្ឋអាមេរិកបានចាប់ផ្ដើមផ្សាយព័ត៌មានក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ជាការឃោសនាប្រឆាំងនឹងពួកកុម្មុយនិស្ត ហើយជាធម្មតាត្រូវគេទប់ស្កាត់នៅប្រទេសចិន គឺត្រូវគេវាយប្រហារជាសាធារណៈនិងតាមផ្លូវច្បាប់។ ដោយទទួលរងការចោទប្រកាន់ថាជាផ្នែកនៃការឃុបឃិតរបស់អាមេរិក ដើម្បីផ្ដួលរំលំ ហ៊ុន សែន នោះ ការផ្សាយរបស់វិទ្យុនេះត្រូវគេបញ្ឈប់ ហើយអ្នកកាសែតជាជនជាតិខ្មែរពីរនាក់ក្នុងចំណោមអ្នកកាសែតជាជនជាតិខ្មែរទាំងអស់របស់វិទ្យុនេះត្រូវបានចាប់ខ្លួនពីបទចារកម្ម។ វិទ្យុដែលគាំទ្រដោយសហរដ្ឋអាមេរិកក៏ដូចគ្នាដែរ គឺសំឡេងសហរដ្ឋអាមេរិក (វីអូអេ) ក៏ត្រូវបានរារាំងមិនឲ្យផ្សាយតាមស្ថានីយ៍វិទ្យុក្នុងស្រុកផងដែរ បើទោះបីជានៅពេលសរសេររបាយការណ៍នេះ ការិយាល័យព័ត៌មានរបស់ វីអូអេ នៅបន្តដំណើរការនៅក្រុងភ្នំពេញនៅឡើយក្ដី។ វិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) ដែលជាវិទ្យុមិនស្វែងរកផលកម្រៃរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក៏ត្រូវបានបង្អាក់ដំណើរការដែរ។ វិទ្យុសំឡេងប្រជាធិបតេយ្យត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ហើយផ្ដល់មូលនិធិដោយម្ចាស់ជំនួយបរទេស។ វិទ្យុអាស៊ីសេរី សំឡេងសហរដ្ឋអាមេរិក និងសំឡេងប្រជាធិបតេយ្យនៅបន្តបង្ហោះព្រឹត្តិបត្រព័ត៌មានតាមអនឡាញដដែល ហើយវីអូអេខ្មែរក៏មានអ្នកមើលលើទំព័រហ្វេសប៊ុកដ៏មានប្រជាប្រិយចំនួន ៦,២លាននាក់ដែរ។

## កាសែតបោះពុម្ព

ការសែតបោះពុម្ពបានបន្តធ្លាក់ចុះជាបន្តបន្ទាប់ ក៏ប៉ុន្តែការធ្លាក់ចុះនេះត្រូវបានស្ដារមកវិញដោយកំណើននៃអត្ថបទឌីជីថលដ៏ខ្លាំងគួរសមរបស់កាសែតមួយចំនួនទៅវិញ។ យោងតាមគម្រោងពិនិត្យមើលម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយ កាសែតកោះសន្តិភាព ដែលជាកាសែតដ៏ពេញនិយមបំផុតនៅប្រទេសនេះបានគ្រប់គ្រងវេបសាយកម្ពុជាដ៏ពេញ

និយមបំផុតមួយក្នុងចំណោមវេបសាយកម្ពុជាដ៏ពេញនិយមបំផុតទាំងអស់។ ការសែត ដើមអម្ពិល ដែលមានការបោះពុម្ពត្រឹមតែ ២% នោះក៏មានវេបសាយដ៏ពេញនិយមមួយក្នុងចំណោមវេបសាយទាំង ១០ ដែរ។

ទោះជាយ៉ាងនេះក្តី គម្រោងពិនិត្យមើលម្ចាស់កម្មសិទ្ធិប្រព័ន្ធផ្សព្វផ្សាយកត់សម្គាល់ថា កាសែតក្នុងស្រុកជាច្រើនក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សកាន់អំណាចដែរ។ គម្រោងនេះបញ្ជាក់ថា កោះសន្តិភាពមានអ្នកយកព័ត៌មានច្រើន ដែលធ្វើការនៅក្រសួងមហាផ្ទៃ ចំណែកឯកាសែតរស្មីកម្ពុជាវិញជាកម្មសិទ្ធិរបស់លោក សាយ ឈុំ ប្រធានព្រឹទ្ធសភា ហើយកាសែតកម្ពុជាថ្មីជាកម្មសិទ្ធិរបស់អ្នកស្រី ហ៊ុន ម៉ាណា។

ក្នុងចំណោមកាសែតជាភាសាអង់គ្លេស  កាសែត ភ្នំពេញប៉ុស្តិ៍ ដែលជាកម្មសិទ្ធិរបស់ជនជាតិអូស្ត្រាលី គឺត្រូវគេចាត់ថាជាអង្គភាពសារព័ត៌មានឯករាជ្យបំផុតមួយក្នុងចំណោមអង្គភាពសារព័ត៌មានឯករាជ្យបំផុតនៅប្រទេសនេះ ហើយកាសែតនេះក៏ផ្សាយជាភាសាខ្មែរដ៏ពេញនិយមដែរ នោះគឺប៉ុស្តិ៍ខ្មែរ បើទោះបីអត្ថបទជាភាសាខ្មែរខុសពីភាសាអង់គ្លេសក្តី។ ខ្មែរ ថៃមស៍ ជាកាសែតថ្មីទទួលបានកេរ្តិ៍ឈ្មោះបោះសំឡេងពីអ្នកអាន ជាពិសេសក្នុងចំណោមជនបរទេស ថាលម្អៀងទៅរករដ្ឋាភិបាល។ អ្នកសារព័ត៌មានបរទេសឲ្យចំណាត់ថ្នាក់កាសែតនេះ៤,១ក្នុងបណ្តា៥ពិន្ទុ (ងាកទៅរកកំរិត "មិនដែលឯករាជ្យ") ចំណែកឯអ្នកកាសែតជនជាតិខ្មែរវិញឲ្យពិន្ទុកាសែតនេះមធ្យម គឺ ៣,១ ដែលជាការខុសឃ្លាតគ្នាឆ្ងាយនៅក្នុងការស្ទង់មតិ។ (វេបសាយ "ថ្មីៗ" និង "ខាមបូណ្ឌមិស" ក៏ត្រូវចាត់ទុកថាសរសេរខ្លាំងៗដែរដោយជនបរទេស)។ ជាចុងបញ្ចប់ កាសែត ឌឹខេមបូឌា ដេលី ដែលទទួលបានការគោរពថាមានវិជ្ជាជីវៈសារព័ត៌មាន និងទទួលបានចំណាត់ថ្នាក់ថាឯករាជ្យបំផុតនៅឆ្នាំនេះដោយអ្នកសារព័ត៌មានដែលស្ទង់មតិនោះ គឺលែងបោះពុម្ពផ្សាយក្នុងខែកញ្ញា ដោយសារតែបញ្ហាពន្ធ។

## សមាគមអ្នកសារព័ត៌មាន

ក្លិបអ្នកកាសែតកម្ពុជា (កអក) ដែលមានយូរណាស់មកហើយ។ ក្លិបអ្នកកាសែតកម្ពុជាដឹកនាំដោយលោក ប៉ែន បូណា និពន្ធនាយកនៃទូរទស្សន៍ភីអិនអិនរបស់លោក លី យុងផាត់ សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា។ សមាគមដែលទើបបង្កើតថ្មីៗដូចជា សហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ស.ស.ស.ក)  បង្កើតឡើង និងដឹកនាំដោយលោក ហ៊ុយ វណ្ណៈ អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានសមាសភាពពីសមាគមអ្នកកាសែតធំៗនៅក្នុងប្រទេស។ សហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជាបានទទួលការគាំទ្រយ៉ាងឆាប់រហ័ស ហើយឥឡូវនេះអះអាងថាមានសមាជិកជាង១០០០ នាក់។ ទោះជាកម្ពុជាមានសមាគមអ្នកសារព័ត៌មានមួយចំនួនរួចមកហើយក្តី ក៏គ្មានសមាគមណាមួយហ៊ានចេញមកនិយាយអ្វីនោះទេក្នុងពេលដែលមានការចាប់ខ្លួនអ្នកកាសែតនៅឆ្នាំនេះ។ បន្ថែមពីលើនេះនៅមានសមាគមតូចមួយទៀត នោះគឺសមាគមកម្ពុជាការពារអ្នកកាសែត ។ សមាគមនេះមានសមាសភាពពីអ្នកកាសែតជនជាតិខ្មែរដែលធ្វើការនៅអង្គភាពសារព័ត៌មានបរទេស។

## ចំណាត់ថ្នាក់

របាយកាណ៍ថ្មីបំផុតស្តីពីសេរីភាពប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការផ្ទះសេរីភាពនិងអ្នកកាសែតគ្មានព្រំដែន ដែលរបាយការណ៍របស់អង្គការទាំងពីរចេញផ្សាយ មុននឹងការបិទអង្គភាពសារព័ត៌មាននានានៅកម្ពុជានោះ  បានចាត់ទុកប្រព័ន្ធផ្សព្វផ្សាយកម្ពុជាថា "មិនសេរី" ដោយទទួលបានចំណាត់ថ្នាក់ទី១៣២ថាមានលក្ខណៈសេរីតិចតួចបំផុតក្នុងចំណោមប្រទេសចំនួន១៨០។ អ្នកកាសែតគ្មានព្រំដែននិយាយថា ទោះបីប្រទេសកម្ពុជាមានចំណាត់ថ្នាក់ខ្ពស់ជាងប្រទេសជិតខាង ដូចជា ថៃ ឡាវ និងវៀតណាមក្តី ក៏ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជានៅតែ "ស្ថិតក្រោមការឃ្លាំមើលជិតដល់"ដោយរដ្ឋាភិបាល។ អ្នកសារព័ត៌មាន៩០%ដែលបានស្ទង់មតិបាននិយាយថាពួកគេបានយល់ស្របខ្លះៗនឹងការវាយតម្លៃរបស់ផ្ទះសេរីភាព។

# ការប្រឈមរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

"អាជ្ញាធរបានព្រមានយើងថា៖ កុំចេះតែហ៊ានពេក"

## ការគំរាមកំហែង និងការចាប់ដាក់ពន្ធនាគារគឺជារឿងធម្មតាឬ?

នៅដើមខែកុម្ភៈលោក កឹម សុខ អ្នកវិភាគនយោបាយបានចូលរួមពិភាក្សាតុមូលនៅវិទ្យុអាស៊ីសេរី ហើយក៏បានរិះគន់គណបក្សប្រជាជនកម្ពុជា។ អ្នកវិភាគរូបនេះបាននិយាយថា "គេ" បានសម្លាប់ កែម ឡី អ្នករិះគន់រដ្ឋាភិបាលដ៏មានប្រជាប្រិយភាពម្នាក់ កាលពីខែកក្កដា ឆ្នាំ២០១៦។ ដោយនៅតែបន្តជំហររឹងត្អឹងជាសាធារណៈ កឹម សុខ បន្តរិះគន់ខ្លាំងៗទៅលើរដ្ឋាភិបាល ក្នុងពេលដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្ដឹងលោកឡើងតុលាការ ហើយលោកក៏ត្រូវតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារពីបទញុះញង់និងបរិហារកេរ្តិ៍។

តើលោកអ្នកធ្លាប់ទទួលរងការវាយប្រហារឬទេ?

តាមផ្លូវកាយ/តាមពាក្យសម្ដី




តើលោកអ្នកធ្លាប់ត្រូវគេគំរាមកំហែងឬទេ?

តាមផ្លូវកាយ/តាមពាក្យសម្ដី/តាមផ្លូវច្បាប់




រយៈពេល៣ខែក្រោយមក រដ្ឋាភិបាលបានជួបមេដឹកនាំថ្នាក់តំបន់និងអ្នកសារព័ត៌មានអន្តរជាតិនៅទីក្រុងភ្នំពេញក្នុងឱកាសវេទិកាសេដ្ឋកិច្ចពិភពលោកស្ដីពីអាស៊ាន ហើយលោក ហ៊ុន សែន ក៏បានធ្វើសន្និសីទកាសែតមួយនៅឯសណ្ឋាគារផ្កាយ ៥ សុខា នៅជ្រោយចង្វា។ លោកនាយករដ្ឋមន្ត្រីបានឆ្លើយតបនឹងសំណួរពីរ គឺសំណួរមួយសួរដោយអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី និងសំណួរមួយទៀតសួរដោយអ្នកយកព័ត៌មានពាណិជ្ជកម្មនៃកាសែត ឌឺខេមបូឌាដេលី ដែលសំណួរទាំងពីរទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច។ លោក ហ៊ុន សែន បានប្រើពេលមួយចំនួនក្នុងសន្និសីទកាសែតដែលមានរយៈពេល៣៧នាទី ក្នុងការស្ដីបន្ទោសអ្នកយកព័ត៌មានទាំងពីរនាក់នោះ ដោយព្រមានថា ពួកគេគឺជា "ខ្ញុំបម្រើបរទេស" ។

បើនិយាយអោយអស់ទៅ នេះជារឿងរ៉ាវដែលកើតមានឡើងជាធម្មតាទៅហើយ។

កឹម សុខ គឺជាមនុស្សទីបីហើយដែលត្រូវផ្ដន្ទាទោសដោយសារតែបានភ្ជាប់ឃាតកម្មលើលោក កែម ឡី ទៅនឹងគណបក្សប្រជាជនកម្ពុជា (ពីរនាក់ផ្សេងទៀត គឺជាអ្នកនយោបាយដែលបានគេចខ្លួនទៅបរទេស) ហើយវិទ្យុអាស៊ីសេរី

ដែលស្និទ្ធស្នាលនឹងបក្សប្រឆាំង និងដែលផ្ដល់មូលនិធិដោយសហរដ្ឋអាមេរិកនោះ ជារឿយៗក៏ក្លាយជាមុខសញ្ញានៃសម្ដីវាយប្រហារខ្លាំងៗរបស់លោក ហ៊ុន សែនផងដែរ។ ក៏ប៉ុន្ដែទោះជាយ៉ាងនេះក្ដី ក៏វិទ្យុអាស៊ីសេរីនៅតែបន្ដធ្វើការដដែលលើកលែងតែមានការហាមប្រាមមួយរយៈពេលខ្លីក្នុងអំឡុងពេលបោះឆ្នោតជាតិនាឆ្នាំ២០១៣ប៉ុណ្ណោះ។

ឧប្បត្តិហេតុដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយជាច្រើនទៀតបានកើតឡើងក្នុងរយៈពេល៦ខែដើមឆ្នាំនេះ។ ពលរដ្ឋខ្មែរជាច្រើនត្រូវចាប់ខ្លួនដោយសារតែរិះគន់លោកនាយករដ្ឋមន្ត្រីតាមបណ្ដាញសង្គមហ្វេសប៊ុក (សូមមើលអត្ថបទអមទាក់ទងនឹងការចាប់ខ្លួនដោយសារហ្វេសប៊ុក p 18) ។ អ្នកសារព័ត៌មាននៅតាមខេត្តភាគច្រើនដែលមានអង្គភាពសារព័ត៌មានមិនប្រាកដត្រូវតុលាការចោទប្រកាន់ពីបទជំរិតទារប្រាក់ពីឈ្មួញរកស៊ីឈើ និងកសិករដែលប្រកបការងារកសិកម្មនៅលើដីធ្លីដែលគ្រប់គ្រងដោយរដ្ឋ (អត្ថបទអមអ្នកជំរិតទារប្រាក់ p 22) ។ អ្នកយកព័ត៌មានវិទ្យុអាស៊ីសេរី គឺលោក ហួត វុទ្ធី ដែលគេស្គាល់តាមវិទ្យុថាឈ្មោះ ជុន ចន្ទ័បុត្រ បានគេចខ្លួនចេញពីប្រទេស ដើម្បីគេចពីដីកាតាមចាប់ខ្លួន ដោយសារតែលោកបង្ហាញអត្តសញ្ញាណក្លែងបន្លំនៅខណៈពេលដែលលោកចូលទៅសាកសួរសុខទុក្ខក្រុមអ្នកនយោបាយបក្សប្រឆាំងនៅពន្ធនាគារព្រៃសកាលពីខែមេសា ឆ្នាំ ២០១៧ កន្លងទៅនេះ។ លោក សាំង សុតន្ទ្រវិទ្ធ អតីតអ្នកយកព័ត៌មាន ឌឺខេមបូឌា ដេលី បានចោទអតីតចៅហ្វាយរបស់លោកថាមិនបានផ្ដល់ប្រាក់បំណាច់ដល់លោក បន្ទាប់ពីលោកបានធ្លាក់ខ្លួនឈឺក្នុងឆ្នាំ២០១៦ ហើយបានអះអាថាគេឲ្យគាត់ឈប់សម្រាក់ពីការងារដោយគ្មានប្រាក់ខែ។ លោកបានទទួលអំណោយជាថវិកាភ្លាមៗពីលោកនាយករដ្ឋមន្ត្រីនិងមន្ត្រីផ្សេងទៀត ក្រោយពីលោកបានចេញមកនិយាយជាសាធារណៈ។

នៅពេលបោះឆ្នោតឃុំសង្កាត់ក្នុងមិថុនា អ្នកយកព័ត៌មានកាសែតដេលី ពីរនាក់ គឺលោក អូន ភាព និងលោក ហ្សែមបូ ភីធី បានក្លាយជាគោលដៅនៃបណ្ដឹងតុលាការ ដែលចោទអ្នកកាសែតទាំងពីរថាញុះញង់ប្រជាពលរដ្ឋឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ អ្នកកាសែតទាំងពីរនាក់បានសម្ភាសន៍អ្នកភូមិនៅខេត្តរតនគីរី ជាផ្នែកមួយនៃការសេសេរអត្ថបទអំពីការបោះឆ្នោត ដោយសួរសំណួរផ្សេងៗ មានដូចជា "តើអ្នកភូមិបោះឆ្នោតឲ្យបក្សណាក្នុងឆ្នាំ២០១២?" ទន្ទឹមនឹងនោះលោក ជេម រិកគិតសុន (James Ricketson) ជាផលិតករខ្សែភាពយន្តជនជាតិអូស្ត្រាលី ត្រូវបានចាប់ខ្លួនមួយថ្ងៃ បន្ទាប់ពីគេបានឃើញលោកបង្ហោះយន្តហោះគ្មានមនុស្សបើកនៅកន្លែងប្រមូលផ្ដុំគ្នារបស់បក្សប្រឆាំង។ ផលិតករខ្សែភាពយន្តរូបនេះត្រូវបានចោទប្រកាន់ពីបទសើបការណ៍សម្ងាត់ ហើយក៏ប្រឈមនឹងការជាប់ពន្ធនាគាររយៈពេល១០ឆ្នាំដែរ។

ឧប្បត្តិហេតុទាំងអស់នេះក៏បានបន្ថែមទម្ងន់ទៅលើស្ថានការណ៍តានតឹងដែរ។ អ្នកសារព័ត៌មានត្រូវគេឃាយី និងគំរាមកំហែង ហើយតុលាការក៏ចាត់វិធានការធ្ងន់ធ្ងរ ដោយគ្រាន់តែសំអាងលើលេសមិនគួរឲ្យជឿប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្ដី ក៏ការគំរាមកំហែងនិងការវាយប្រហារទៅលើអ្នកសារព័ត៌មានកំពុងកើតឡើងវិញនៅកម្ពុជា។ មានអ្នកសារព័ត៌មាន៣៨%នៃអ្នកសារព័ត៌មានដែលបានស្ទង់មតិបាននិយាយថា ពួកគេទទួលរងការវាយប្រហារជាពាក្យសម្ដី ឬតាមផ្លូវកាយ ក្នុងពេលបំពេញការងារនៅកម្ពុជា ឯអ្នកសារព័ត៌មាន៤៧%បាននិយាយថា ពួកគេទទួលរងការគំរាមកំហែងនៅពេលខ្លះ។ និន្នាការនេះគឺកើនឡើងពី២៦%និង២៩%ក្នុងឆ្នាំ២០១៥។ តួលេខគឺមាន១៤%និង២០%រៀងគ្នាចំពោះការវាយប្រហារនិងការគំរាមកំហែងក្នុងឆ្នាំកន្លងមក។

"ការបង្ក្រាប"

ជាផ្លូវការ ប្រទេសកម្ពុជាក្លាយជាប្រទេសប្រកាន់ប្រជាធិបតេយ្យសេរីពហុបក្សតាំងពីឆ្នាំ១៩៩៣មកម្ល៉េះ។ ប្រទេសនេះក៏មានសារព័ត៌មានសេរីដែរ ដោយមានកាសែតជាភាសាអង់គ្លេស ភ្នំពេញប៉ុស្តិ៍ និង ឌឹខេមបូឌា ដេលី ត្រូវបង្កើតឡើងនៅពេលនោះដែរ។ ទោះជាយ៉ាងនេះក៏ដោយ លក្ខណៈបំភាន់ទាំងនេះក៏បានបាត់បង់ទៅវិញក្នុងរយៈពេល៦ខែចុងឆ្នាំ២០១៧។

នៅថ្ងៃទី៥ ខែសីហា វិក្កយបត្របង់ពន្ធដែលបានផ្សព្វផ្សាយដោយសារព័ត៌មាន Fresh News អះអាងថា ម្ចាស់កាសែត ឌឹខេមបូឌា ដេលី ជំពាក់ពន្ធរដ្ឋចំនួន៦,៣ លានដុល្លារក្នុងរយៈពេល១០ឆ្នាំកន្លងមក។ ម្ចាស់កាសែតនេះបានអះអាងថា វិក្កយបត្របង់ពន្ធនោះបានបង្ហោះលើ Fresh News មុននឹងបញ្ជូនទៅដល់ម្ចាស់កាសែត។ ម្ចាស់កាសែតក៏បានអះអាងទៀតថា ពុំមានសវនកម្មបញ្ជីស្នាមណាមួយដែលអាចបញ្ជាក់ថានេះជាតួលេខពិតប្រាកដ សម្រាប់ពន្ធរយៈពេល១០ឆ្នាំនោះទេ។

ប៉ុន្មានសប្តាហ៍ក្រោយមកទៀត វិទ្យុអាស៊ីសេរីនិងវីអូអេក៏ត្រូវសើបអង្កេតបញ្ហាបង់ពន្ធស្រដៀងគ្នានេះដែរ។ នៅថ្ងៃទី១៩ ខែសីហា លោក គង់ វិបុល អគ្គនាយកពន្ធបានប្រាប់ Fresh News ថា កាសែតដេលីនឹងត្រូវបិទនៅថ្ងៃទី៤ ខែកញ្ញា ប្រសិនបើមិនបានបង់ពន្ធទេ។ បីថ្ងៃក្រោយមកលោក ហ៊ុន សែន បានហៅកាសែតនេះថាជា "មេចោរ"។ រឿងរ៉ាវទាក់ទងនឹងការឃុបឃិតក្នុងបដិវត្តពណ៌ក៏ត្រូវបានសរសេរយ៉ាងច្រើនក្រាស់ក្រែលដោយ Fresh News នៅក្នុងអំឡុងពេលនោះដោយភ្ជាប់ក្រុមគ្រួសារលោក កឹម សុខា មេបក្សប្រឆាំង អ្នកសារព័ត៌មានបរទេស ទីភ្នាក់ងារសើបការណ៍សហរដ្ឋអាមេរិក និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយចំនួនទៅនឹងផែនការដែលគេចោទថាធ្វើឡើងដើម្បីផ្តួលរំលំរដ្ឋាភិបាល។ លោក ហ្គិហ្វ គេន អ្នកកាសែតជនជាតិអាមេរិកាំង ដែលមានមូលដ្ឋាននៅក្រៅប្រទេសកម្ពុជាបានទទួលរងការចោទប្រកាន់ថាលោកជាចារបុរស។ ចំណែកឯវិទ្យាស្ថានជាតិប្រជាធិបតេយ្យដែលជាអង្គការសង្គមស៊ីវិលធ្វើការងារផ្នែកកិច្ចការបោះឆ្នោតដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិកត្រូវបណ្តេញចេញពីប្រទេសនេះ។ វិទ្យុអាស៊ីសេរី និងវីអូអេ ក៏ត្រូវចោទប្រកាន់ថាជាឧបករណ៍សមគំនិតគ្នា។

> "វាមិនមែនជារឿងនយោបាយទេ។ កាសែតនិងវិទ្យុទាំងនោះមិនបានផ្សាយនូវសមិទ្ធផលរបស់រដ្ឋាភិបាលទេ ប៉ុន្តែតែងតែរាយការណ៍ពីកំហុសរបស់រដ្ឋាភិបាល"

នៅថ្ងៃទី២១ ខែសីហា មានស្ថានីយ៍វិទ្យុជាង១០ដែលជួលម៉ោងផ្សាយឲ្យវិទ្យុអាស៊ីសេរី វីអូអេ វីអូឌី និងអត្ថបទគណបក្សសង្គ្រោះជាតិក៏ត្រូវបានបញ្ជាឲ្យបិទដែរ។ ក្នុងពេលចំនួនស្ថានីយ៍ដែលបិទបានកើនឡើងដល់៣២ស្ថានីយ៍ ក្រោយពីបិទការផ្សាយព័ត៌មានឯករាជ្យនិងព័ត៌មានបក្សប្រឆាំងតាមរលកធាតុអាកាសនោះ ក្រសួងព័ត៌មានក៏បានពន្យល់ជាទូទៅថា ស្ថានីយ៍ទាំងនោះបានរំលោភបំពានលើកិច្ចសន្យាជាមួយរដ្ឋាភិបាល។

តើការបិទប្រព័ន្ធផ្សព្វផ្សាយច្រើនតែជារឿងនយោបាយឬ?



■ ជារឿងនយោបាយ 92%
■ ជារឿងនយោបាយខ្លះៗ 4%
■ អត់ទេ 4%

នៅថ្ងៃទី៣ ខែកញ្ញា លោក កឹម សុខា មេដឹកនាំបក្សប្រឆាំងត្រូវបានចាប់ខ្លួននៅឯគេហដ្ឋានផ្ទាល់របស់លោកពីបទក្បត់ជាតិ។ ឯកាសែត ឌឹខេមបូឌា ដេលី បានចេញផ្សាយលេខចុងក្រោយរបស់ខ្លួននៅព្រឹកបន្ទាប់ ដោយម្ចាស់កាសែតអះអាងថា ពួកគេមិនមានថវិកាបន្តដំណើរការទៅមុខទៀតទេ។ ប៉ុន្មានសប្តាហ៍ក្រោយមក វិទ្យុអាស៊ីសេរីក៏បានបិទទីស្នាក់ការយកព័ត៌មាននៅភ្នំពេញរបស់ខ្លួនដែរ។

អ្នកសារព័ត៌មានចំនួន៩២%បាននិយាយថា ការបិទអង្គភាពសារព័ត៌មានទាំងនោះគឺទាក់ទងនឹងរឿងនយោបាយ។ អ្នកសារព័ត៌មានមួយរូបបាននិយាយថា "ប្រហែលជាមានអង្គការជាច្រើននៅកម្ពុជាដែលមិនបានបង់ពន្ធ ហើយគេក៏មិនបានបង្ខំឲ្យចាកចេញពីប្រទេសដែរ។ តាមពិត មានការបោះឆ្នោតនៅឆ្នាំក្រោយ ហើយរឿងនេះហាក់ដូចជាកើតឡើងស្របពេលគ្នាពេក"។

អ្នកសារព័ត៌មានមួយរូបទៀតបាននិយាយថា "នេះជាការត្រៀមបង្ក្រាបជាទ្រង់ទ្រាយធំទៅលើបក្សប្រឆាំង"។

## ការបន្តចាប់ខ្លួន

ការយាយីអ្នកសារព័ត៌មាននៅតែបន្តកើតមានខណៈដែលគណបក្សសង្គ្រោះជាតិត្រូវបានរម្លាយដោយសេចក្តីសម្រេចរបស់តុលាការកំពូលកាលពីថ្ងៃទី១៦ខែវិច្ឆិកាដោយផ្អែកលើការចោទប្រកាន់ថាបានឃុបឃិតជាមួយបរទេសដែលត្រូវបានគេផ្តោតលើលោក កឹម សុខា។

> "គ្មានសេរីភាពទេ.... អ្នកប្រឈមការចាប់ដាក់ពន្ធនាគារដោយគ្រាន់តែសរសេរបញ្ចេញយោបល់នៅលើហ្វេសប៊ុក។ យើងមិនអាចសូម្បីតែនិយាយពីអ្វីដែលអ្នកអាចសរសេរសម្រាប់កាសែតផង"

អតីតអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីពីរនាក់គឺលោក អួន ឈិន និងលោក យៀង សុជាមេត្តា ត្រូវបានឃាត់ខ្លួនពីរថ្ងៃមុន ដោយចោទប្រកាន់ថាអ្នកទាំងពីរបានបន្តរាយការណ៍ព័ត៌មានឱ្យវិទ្យុអាមេរិក ខណៈអ្នកយកព័ត៌មានពីរនាក់ទៀតគឺ Andrew Nachemson បម្រើការងារឱ្យកាសែត ភ្នំពេញ ប៉ុស្តិ៍ និងកញ្ញា ឡេង ឡៃន អតីតអ្នកយកព័ត៌មានឱ្យកាសែត ឌឹខេមបូឌា ដេលី ត្រូវបានឃាត់ខ្លួននៅថ្ងៃដែលតុលាការកំពូលបើកសវនាការ ដោយសារមិនមានលិខិតសម្គាល់អត្តសញ្ញាណ ឬប័ណ្ណព័ត៌មានត្រឹមត្រូវ។ ក្រោយមកពួកគេត្រូវបានដោះលែងវិញ។

អ្នកយកព័ត៌មានពីរនាក់របស់កាសែត ឌឹខេមបូឌា ដេលី ដែលប្រឈមការចោទប្រកាន់ក្នុងខេត្តរតនគិរី ហើយបើតាមព័ត៌មានបានអោយដឹងថា អ្នកទាំងពីរបានចាកចេញពីប្រទេសទៅហើយ ខណៈដែលអតីតអ្នកយកព័ត៌មានវិទ្យុអាស៊ីសេរីប្រចាំរាជធានីភ្នំពេញបាននិយាយថា ពួកគេកំពុងត្រូវគេឃ្លាំមើលនិងតាមដាន។ អ្នកសារព័ត៌

មានភាគច្រើនបានប្ដូរលេខទូរស័ព្ទរបស់ខ្លួន ហើយមិនអាចទាក់ទងបានឡើយ។

អ្នកសារព័ត៌មានដែលត្រូវបានស្ទាបស្ទង់មតិ មិនដឹងច្បាស់ថាការបន្តបង្ក្រាបនោះឆ្ពោះទៅកន្លែងណានោះទេ ហើយ៣៣ % បាននិយាយថា ពួកគេរំពឹងថា នឹងមានប្រព័ន្ធផ្សព្វផ្សាយជាច្រើនទៀតត្រូវបិទ។ ចំណែក២៥ភាគរយបាននិយាយថា អ្វីៗបានបញ្ចប់រួចហើយ។

អ្នកសារព័ត៌មានម្នាក់បាននិយាយថា "គេបានបោសសម្អាតរាល់ខ្លឹមសារព័ត៌មានប្រឆាំងនៅតាមរលកធាតុអាកាសរួចទៅហើយ ហើយគេបានធ្វើជាកាសែត និងវិទ្យុគំរូ។ ខ្ញុំគិតថា ប្រជាពលរដ្ឋទទួលបានសារនេះ"។

អ្នកសារព័ត៌មានផ្សេងទៀតមិនយល់ស្របដូចនេះទេ។ អ្នកផ្ដល់បទសម្ភាសន៍ម្នាក់បាននិយាយថា "ខ្ញុំគ្រាន់តែគិតថា ការបង្ក្រាបលើសំឡេងរិះគន់កំពុងតែកើនឡើង"។ អ្នកផ្ដល់បទសម្ភាសន៍ម្នាក់ទៀតបានចែករំលែកការព្រួយបារម្ភរបស់ខ្លួនថា គ្មានវិធីណាដែលអាចរារាំងលោក ហ៊ុន សែន បានឡើយ។ "គាត់ហ៊ានរម្លាយសូម្បីតែគណបក្សប្រឆាំងដ៏ធំមួយ  ចុះទម្រាំយើងជាប្រព័ន្ធផ្សព្វផ្សាយតូចតាចនោះ?"

វិទ្យុអាស៊ីសេរី វីអូអេ និងវិទ្យុសំឡេងប្រជាធិបតេយ្យនៅតែបន្តផ្សាយព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃនិងខ្លឹមសារព័ត៌មានដទៃទៀតនៅលើបណ្ដាញអ៊ីនធឺណិតខណៈពេលដែលសារព័ត៌មានខេមបូឌាដេលីបានបង្ហោះព័ត៌មានថ្មីៗលើគេហទំព័រ និងទំព័រហ្វេសប៊ុករបស់ខ្លួន។

## ភាពស្ងៀមស្ងាត់ និងវិបត្តិផ្លូវចិត្ត

អ្នកសារព័ត៌មានដែលបន្តធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានប្រឈមនឹងការដាក់សម្ពាធកាន់តែខ្លាំងឡើង។

អ្នកសារព័ត៌មានម្នាក់បាននិយាយថា "នៅពេលយើងចេញទៅយកព័ត៌មានម្ដងៗ យើងត្រូវបានរារាំងដោយអាជ្ញាធរ។ ពួកគេគំរាមកំហែងយើង"។ អ្នកសារព័ត៌មានម្នាក់ទៀតបានឱ្យដឹងថា "ចំពោះបណ្ដាញព័ត៌មានដែលមិនគាំទ្ររដ្ឋាភិបាល វាពិបាកក្នុងការចូលទៅកន្លែងមួយចំនួនដើម្បីទទួលបានព័ត៌មានណាស់ ហើយត្រូវសារព័ត៌មានទាំងនោះត្រូវបានគេតាមឃ្លាំមើលទៀតផង"។

អ្នកសារព័ត៌មានភាគច្រើនបាននិយាយថា ពួកគេមានអារម្មណ៍ថា ពួកគេត្រូវបានគេឃ្លាំមើល។អ្នកសារព័ត៌មានបានរាយការណ៍ថា អាជ្ញាធរបានថតរូបពួកគេនៅពេលដែលពួកគេកំពុងបំពេញការងារ ហើយត្រូវបានរារាំងមិនឱ្យចូលទៅក្នុងរដ្ឋសភានិងទីកន្លែងដទៃទៀត។ ពួកគេបាននិយាយថា ក្រុមអាជ្ញាធរមានបំណងរកលេសដើម្បីធ្វើទុក្ខបុកម្នេញដល់ពួកគេ។

អ្នកយកព័ត៌មានបាននិយាយថា "យើងមានការប្រុងប្រយ័ត្នខ្លាំងណាស់ នៅពេលយើងរាយការណ៍ព័ត៌មាន។ យើងព្យាយាមធ្វើយ៉ាងណាកុំឱ្យមានកំហុស។យើងគោរពតាមគោលការណ៍សារព័ត៌មានយ៉ាងតឹងរ៉ឹងដើម្បីធានាថារដ្ឋាភិបាលមិនអាចចាប់កំហុសយើងបាន"។

អ្នកសារព័ត៌មាននៅប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលត្រូវបានគេចាត់ទុកថា ជាអ្នកសារព័ត៌មានឯករាជ្យនោះ គឺប្រហែលមានទំនោរច្រើនជាងពីរដងធៀបនឹងអ្នកសារព័ត៌មានទូទៅក្នុងការទទួលរងការវាយប្រហារដោយពាក្យសម្ដី ឬលើរាងកាយនៅឆ្នាំនេះ។ អ្នកសារព័ត៌មានប្រភេទនេះមានចំនួនអោយ ២០ % បើប្រៀបធៀបទៅនឹងអ្នកសារព័ត៌មានដែលបម្រើការងារនៅតាមស្ថាប័ននានាបានដាក់ចំណាត់ថ្នាក់ថាគ្មានសេរីភាពចំនួន ៧ ភាគរយ។

### វិធីសាស្ត្រទំនាក់ទំនង




*វ៉ាត់ស៍អាប់/តេឡេក្រាម/សិកណល គឺមានដាក់លេខកូដសម្ងាត់។

"ពួកគេគួរដកថយ។ ពួកគេមិនគួរតស៊ូប្រឆាំងនឹងរដ្ឋាភិបាលទេ។ ពួកគេគួរតែទទួលយកនូវអ្វីដែលពួកគេបានធ្វើខុសរហូតមកទល់ពេលនេះ"

ពួកគេបាននិយាយថា បញ្ហារបស់ពួកគេគួបផ្សំដោយការភ័យខ្លាចកើនឡើងនៅក្នុងចំណោមប្រភពរបស់ពួកគេ។ ពួកគេបានបន្តថា "យើងចង់រាយការណ៍ ប៉ុន្តែប្រភពរបស់យើងមិនហ៊ាននិយាយទេ ដូច្នេះខ្លឹមសារអត្ថបទរបស់យើងត្រូវបានថយចុះ"។

អ្នកសារព័ត៌មានមួយចំនួនបាននិយាយថា ប្រភពមួយចំនួនកំពុងទាមទារឱ្យពួកគេប្រើតែការទំនាក់ទំនងដែលបានអ៊ីនគ្រីបរួច (បំបែកជាកូដ) ហើយការកើនឡើងដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាគឺជានិន្នាការមួយគួរឱ្យកត់សម្គាល់។ អ្នកសារព័ត៌មានភាគច្រើនបាននិយាយថា ពួកគេបានប្រើ WhatsApp ដែលបានអ៊ីនគ្រីបរហូតដល់ ៩១% នៃបទសន្ទនា ឬសារទំនាក់ទំនងទាំងអស់ ជាជាងប្រើប្រាស់ការផ្ញើសារជាអក្សរដែលគេស្ទាក់ចាប់បានដោយងាយស្រួលដែលមានកំរិតភាគរយរហូតដល់ទៅ ៨០ % ។ (គេគិតថា សារជាអក្សរត្រូវគេលបលួចចូលទៅមើលបានម្តងហើយម្តងទៀតតាមរយៈគណនីអ៊ីម៉េលនៅប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសសកម្មជន និងអ្នកនយោបាយ)។

៦៧ % នៃអ្នកសារព័ត៌មានបាននិយាយថា ពួកគេមិនមានអារម្មណ៍ថា មានសេរីភាពពេញលេញក្នុងការរាយការណ៍អំពីប្រធានបទទាំងអស់ដោយគ្មានការភ័យខ្លាចពីការជ្រៀតជ្រែក ឬផលវិបាកនានានោះឡើយ ។ និន្នាការនេះកើនឡើងពី៥៨% នៅឆ្នាំ២០១៥ និង៤៧% នៅក្នុងឆ្នាំ២០១៤។

"អ្នកសារព័ត៌មានត្រូវតែប្រុងប្រយ័ត្ន។ ពួកគេប្រឈមនឹងការគំរាមកំហែងដាក់ពាក្យបណ្តឹងគ្រប់ពេលវេលា។ វាអាចកើតឡើងគ្រប់ពេលវេលា"

តើលោកអ្នកគិតថាមានសេរីភាពក្នុងការរាយការណ៍ប្រធានបទទាំងឡាយ ដោយគ្មានការជ្រៀតជ្រែក ឬភ័យខ្លាចការមានបញ្ហាឬទេ?

2017




2015




2014



"នៅពេលនិពន្ធនាយករបស់យើងបានផ្លាស់ប្តូរ [រឿងរបស់យើង] មួយដងឬពីរដង យើងចាប់ផ្តើមយល់ ហើយលើសពីនេះ យើងមានការព្រួយបារម្ភថា មេរបស់យើងនឹងចាត់ទុកយើងជាអ្នកប្រឆាំង"

## ការមិនអាចប៉ះពាល់បាន

ការបែងចែករវាងប្រព័ន្ធផ្សព្វផ្សាយដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅតែមាន ហើយអ្នកសារព័ត៌មានដែលបម្រើការងារនៅតាមប្រព័ន្ធផ្សព្វផ្សាយទាំងនោះត្រូវបានគេចាត់ទុកថា មានឯករាជ្យតិចជាង (អត្រាខ្ពស់ជាង៣ក្នុងចំណោម៥) បានទទួលស្គាល់ថា ពួកគេខ្វះភាពឯករាជ្យ ហើយមានតែ ១៧% ប៉ុណ្ណោះបាននិយាយថា ស្ថាប័នរបស់ពួកគេមានសេរីភាពពីឥទ្ធិពលនយោបាយ និងធុរកិច្ច ធៀបនឹង ៥២% ជាទូទៅ និង៩០% ក្នុងចំណោមអ្នកសារព័ត៌មានដែលបម្រើការងារនៅតាមប្រព័ន្ធផ្សព្វផ្សាយនានាដែលបានវាយតម្លៃដោយមិត្តភក្តិរបស់ពួកគេថា ឯករាជ្យនោះ។ ការយល់ឃើញខ្លួនឯងជាទូទៅគឺត្រូវគ្នានឹងការយល់ឃើញរបស់មិត្តភក្តិពួកគេ  ដែរ។

ពាក់កណ្តាលនៃអ្នកសារព័ត៌មានដែលបម្រើការងារនៅតាមប្រព័ន្ធផ្សព្វផ្សាយដែលមិនសេរីទំនងជានិយាយថា ប្រព័ន្ធផ្សព្វផ្សាយកម្ពុជាកំពុងតែដើរតាមទិសដៅខុស ហើយពួកគេជាមានទំនោរច្រើនរហូតដល់បួនដងក្នុងការដែលនិយាយថាប្រព័ន្ធផ្សព្វផ្សាយនេះទំនងជានៅដដែល។

អ្នកសារព័ត៌មានម្នាក់បាននិយាយថា "សេរីភាពសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានថយចុះ ប៉ុន្តែសម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក គឺនៅដដែល"។

ដោយសំានឹងការជ្រៀតជ្រែកពីសំណាក់ធុរជន និងអ្នកនយោបាយជាច្រើនឆ្នាំមកហើយនោះ អ្នកសារព័ត៌មាននៅស្ថាប័នដែលគាំទ្ររដ្ឋាភិបាលបានប្រកាន់តាមច្បាប់។ មានតែ ៧៨% ប៉ុណ្ណោះក្នុងចំណោមអ្នកដែលផ្តល់បទសម្ភាសន៍នៅតាមប្រព័ន្ធផ្សព្វផ្សាយនានាដែលចាត់ទុកថាមិនសេរីនោះ បាននិយាយថា ស្ថាប័នរបស់ពួកគេយកតែព័ត៌មាននយោបាយប៉ុណ្ណោះ។ ជាទូទៅព័ត៌មាននយោបាយគឺជាប្រភេទព័ត៌មានដែលមានគេយកមកសរសេរតិចបំផុត។

អ្នកយកព័ត៌មានម្នាក់ទៀតបាននិយាយថា "ទេ ខ្ញុំមិនអាចរាយការណ៍អ្វីៗគ្រប់យ៉ាងបានទេ។ យើងត្រូវរាយការណ៍ពីអ្វីៗគ្រប់យ៉ាងថាល្អ"។

នៅក្នុងខែកញ្ញា ទោះបីជាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមួយចំនួនត្រូវបានបិទទ្វារក៏ដោយ ក៏ក្រសួងមហាផ្ទៃបានបើកអោយដំណើរការស្ថានីយ៍ទូរទស្សន៍ផ្ទាល់របស់ខ្លួនមួយជាផ្លូវការគឺស្ថានីយ៍ទូរទស្សន៍ Nice TV ដែលគាំទ្រដោយប្រទេសចិន ខណៈពេលដែលសារព័ត៌មាន Fresh News បានចាប់ផ្តើមសេវាកម្មវិទ្យុតាមប្រព័ន្ធអ៊ីនធឺណិតដោយផ្លាស់ប្តូរតុល្យភាពបន្ថែមទៀតរវាងផ្នែកទាំងពីរនៃឧស្សាហកម្មនេះ។

| | អ្នកសារព័ត៌មាននៅប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ* | នៅប្រព័ន្ធផ្សព្វផ្សាយដែលមិនឯករាជ្យ* |
|---|---|---|
| តើអ្នកចាត់ទុកថាស្ថាប័នព័ត៌មានរបស់អ្នកឯករាជ្យទេ? | បាទ/ចាស 90%; មិនច្បាស់លាស់ 10% | បាទ/ចាស 17%; មិនច្បាស់លាស់ 41%; ទេ 41% |
| តើអ្នកគិតថាមានសេរីភាពក្នុងការរាយការណ៍អំពីប្រធានបទទាំងអស់ទេ? | បាទ/ចាស 55%; មិនច្បាស់លាស់ 45% | បាទ/ចាស 25%; មិនច្បាស់លាស់ 29%; មិនច្បាស់លាស់ 46% |
| តើអ្នកគិតថាប្រព័ន្ធផ្សព្វផ្សាយកម្ពុជាកំពុងដើរក្នុងទិសដៅត្រូវទេ? | ត្រូវ 5%; ដដែល 10%; ខុស 85% | ត្រូវ 14%; ដដែល 43%; ខុស 43% |
| តើអ្នកគិតថាសេរីភាពប្រព័ន្ធផ្សព្វផ្សាយមានការកើនឡើងឬថយចុះក្នុងឆ្នាំកន្លងមកនេះ? | កើនឡើង 0%; ថយចុះ 100% | កើនឡើង 12%; ដដែល 19%; ថយចុះ 69% |
| តើអ្នកត្រូវបានគេវាយប្រហារក្នុងរយៈពេលមួយឆ្នាំកន្លងមកដែរឬទេ? | បាទ/ចាស 20%; ទេ 80% | បាទ/ចាស 7%; ទេ 93% |
| តើអ្នកត្រូវបានគំរាមកំហែងទេក្នុងអំឡុងពេលមួយឆ្នាំកន្លងមកនេះ? | បាទ/ចាស 21%; ទេ 79% | បាទ/ចាស 18%; ទេ 82% |
| តើស្ថាប័នព័ត៌មានរបស់អ្នកយកតែព័ត៌មាននយោបាយទេឬ? | បាទ/ចាស 100%; ទេ 0% | បាទ/ចាស 78%; ទេ 22% |

*ដូចដែលបានចាត់ចំណាត់ថ្នាក់ដោយមិត្តភក្តិ (សូមមើលពិន្ទុឯករាជភាពប្រព័ន្ធផ្សព្វផ្សាយផ្សេង ៗ ទំព័រ ៧)

“ខ្ញុំជឿជាក់លើប្រជាធិបតេយ្យនៃព័ត៌មាន ប៉ុន្តែមានព័ត៌មានក្លែងក្លាយច្រើនណាស់ និងរឿងដែលមិនបានផ្ទៀងផ្ទាត់នៅទីនោះ ហើយជាអកុសល ប្រជាពលរដ្ឋជឿជាក់លើរឿងទាំងនោះ”

**ការចាប់ខ្លួនពាក់ព័ន្ធការបញ្ចេញមតិតាមទំព័រហ្វេសប៊ុក**

ថ្ងៃទី១៣ ខែមិថុនា - លោក លាង ឡា អាយុ៤៥ ឆ្នាំ អនុប្រធានការិយាល័យគណនេយ្យនិងភស្តុភារនៃក្រសួងមហាផ្ទៃត្រូវបានចាប់ខ្លួននៅរាជធានីភ្នំពេញពាក់ព័ន្ធការបញ្ចេញមតិលើទំព័រហ្វេសប៊ុករបស់លោក ហ៊ុន សែន ថា “ហ៊ុនសែនជិតងាប់ហើយ ជាការព្រមានដល់ត្រកូលហ៊ុនទាំងអស់ឱ្យគេចខ្លួនឱ្យហើយទៅមុនឆ្នាំ២០១៨...។ ជោគវាសនារបស់អ្នកត្រូវងាប់ ឬជាប់គុកគឺចៀសមិនផុត”។

ថ្ងៃទី២៧ ខែមិថុនា - ដីកាចាប់ខ្លួនអ្នកស្រី សំ សុខា អាយុ៣៨ ឆ្នាំពីបទញុះញង់ឱ្យមានការរើសអើង និងជេរប្រមាថមន្ត្រីសាធារណៈម្នាក់បន្ទាប់ពីគាត់បានបង្ហោះវីដេអូកាលពីខែមេសាដែលបង្ហាញថា គាត់បានយកស្បែកជើងផ្ទាត់គប់ផ្ទាំងប៉ាណូផ្សព្វផ្សាយដែលមានរូបលោក ហ៊ុន សែន។

ថ្ងៃទី១៣ ខែកក្កដា - លោក ពេជ្រ រដ្ឋា អាយុ២៤ ឆ្នាំត្រូវបានចាប់ខ្លួននៅក្នុងខេត្តព្រះសីហនុបន្ទាប់ពីគាត់បានទៅប៉ុស្តិ៍នគរបាលដើម្បីរាយការណ៍ថា គណនីហ្វេសប៊ុករបស់គាត់ត្រូវបានគេលួចហែកចូល ហើយសរសេរសារគំរាមកំហែងលោកនាយករដ្ឋមន្ត្រីបង្ហោះក្នុងគេហទំព័រនោះ។ សារនោះសរសេរថា “ថ្ងៃណាមួយ អញ

## ការសាយភាយឆាប់រហ័សនៃប្រព័ន្ធឌីជីថល

ការប្រើប្រាស់បណ្ដាញសង្គមបានក្លាយជាស្តង់ដារសម្រាប់គ្រប់ប្រព័ន្ធផ្សព្វផ្សាយរួចទៅហើយ។ ដោយអ្នកផ្តល់បទសម្ភាសន៍ទាំងអស់និយាយថា ស្ថាប័នរបស់ពួកគេប្រើប្រព័ន្ធផ្សព្វផ្សាយសង្គមយ៉ាងហោចណាស់ក៏រាល់សប្តាហ៍ដែរ។ ៨៧% បាននិយាយថា ស្ថាប័នរបស់ពួកគេបានបង្ហោះព័ត៌មាននៅលើបណ្ដាញសង្គមយ៉ាងហោចណាស់៥ដងក្នុងមួយថ្ងៃ។ ហ្វេសប៊ុកត្រូវបានប្រើប្រាស់ដោយមនុស្សទាំងអស់ ហើយចំនួនអ្នកប្រើប្រាស់ Twitter មានប្រហែលពាក់កណ្ដាល ។ មានតែអ្នកឆ្លើយតបម្នាក់ប៉ុណ្ណោះដែលនិយាយថា ប្រព័ន្ធផ្សព្វផ្សាយសង្គមមិនមានប្រយោជន៍ចំពោះយុទ្ធសាស្ត្ររបស់ស្ថាប័នគាត់។

ទោះជាយ៉ាងណាក៏ដោយ ចំនួនកើនឡើងនៃព័ត៌មានតាមបណ្ដាញអ៊ីនធឺណិតបានធ្វើឱ្យមតិយោបល់របស់អ្នកសារព័ត៌មានការបែកខ្ញែក។ ៥៨% នៃអ្នកដែលបានស្ទាប

ការប្រើប្រាស់បណ្ដាញសង្គម (ប្រព័ន្ធផ្សព្វផ្សាយ)







កំណើននៃប្រភពព័ត៌មានតាមអ៊ីនធឺណិតឈានទៅរកៈ



ស្ទង់មតិបាននិយាយថាការកើនឡើងនៃប្រភពព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិតនិងបណ្ដាញសង្គមបានរួមចំណែកដល់សេរីភាពសារព័ត៌មានកាន់តែប្រសើរឡើង។ ៣៨% មិនយល់ស្របដូច្នេះទេ។ មានតែ ៤% ប៉ុណ្ណោះដែលនិយាយថានៅអព្យាក្រឹត។ វាមានផលចំណេញផង និងខាតផង។ មានព័ត៌មានកាន់តែច្រើន អ្នកផ្សព្វផ្សាយក៏មានកាន់តែច្រើន និងទទួលក៏បានព័ត៌មានច្រើន។ ក៏ប៉ុន្តែមនុស្សក៏អាចទទួលបានព័ត៌មានមិនល្អកាន់តែច្រើនដែរ។

អ្នកសារព័ត៌មាននៅក្នុងបន្ទប់ព័ត៌មានមិនទាន់សម័យបាននិយាយថា ការប្រកួតប្រជែងលើអ៊ីនធឺណិតបានធ្វើឱ្យប៉ះពាល់ដល់ការងាររបស់ពួកគេ។ អ្នកយកព័ត៌មានម្នាក់បាននិយាយថា "វាធ្វើឱ្យស្ថាប័នមួយចំនួនរីកចម្រើនទៅមុខដោយសារការផ្ដោតទាំងស្រុងទៅលើកំណើនដ៏លឿនដោយគ្មានការបញ្ជាក់ត្រឹមត្រូវ ដែលធ្វើឱ្យប៉ះពាល់អ្នកដែលធ្វើការផ្ទៀងផ្ទាត់ និងធ្វើការងាររបស់ខ្លួនដោយត្រឹមត្រូវ"។

អ្នកសារព័ត៌មានម្នាក់ទៀតបាននិយាយថា ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនគ្រាន់តែដកស្រង់ដោយមិនធ្វើការរាយការណ៍បន្ថែមអ្វីឡើយ។ ពួកគេគ្រាន់តែចម្លងចេញ ហើយវាដូចជាចម្លងទាំងស្រុងអ៊ីចឹង។

អត្ថបទព័ត៌មានអនាមិកនិងអត្ថបទព័ត៌មានដែលមិនត្រូវបានផ្ទៀងផ្ទាត់បានរាលដាលយ៉ាងឆាប់រហ័សលើគេហទំព័រនិងហ្វេសប៊ុក។ ការចែករំលែករូបភាពក្រាហ្វិកជាញឹកញាប់របស់ជនរងគ្រោះនៃបទឧក្រិដ្ឋ ក៏បង្កឱ្យមានភាពចម្រូងចម្រាសផងដែរ។ រដ្ឋាភិបាលបានចាត់វិធានការមួយចំនួនដើម្បីឆ្លើយតបទៅនឹងអាកប្បកិរិយាតាមប្រព័ន្ធអ៊ីនធឺណិតដោយការចាប់ខ្លួនអ្នករិះគន់លោក ហ៊ុន សែន តាមប្រព័ន្ធផ្សព្វផ្សាយសង្គមដោយផ្អែកលើការចោទប្រកាន់ពីបទញុះញង់ ជេរប្រមាថ និងបទបរិហារកេរ្តិ៍។ ច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតកំពុងត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃនិងក្រសួងទូរគមនាគមន៍ដែលអាចគ្រប់គ្រងវិស័យនេះឱ្យកាន់តែច្បាស់លាស់។

នឹងបាញ់ក្បាលហ្អែង អា សែន អាខ្វាក់"។ "អា សែន ហ្អែងបានសម្លាប់មនុស្សច្រើនណាស់ ហើយមិនយូរទេ ហ្អែងនឹងងាប់ដោយដៃអញមិនខានឡើយ"។

ថ្ងៃទី១៣ ខែសីហា - លោក សួន សេរីរដ្ឋា មេដឹកនាំគណបក្សអំណាចខ្មែរ ត្រូវបានចាប់ខ្លួនពីបទញុះញង់ទាហានកុំឱ្យស្ដាប់បញ្ជា បន្ទាប់ពីលោកបានរិះគន់ការដាក់ពង្រាយកងទ័ពទៅកាន់ព្រំដែនឡាវ។ លោកបានសរសេរនៅលើហ្វេសប៊ុកថា "កូនខ្មែរក្នុងជួរកងទ័ពនឹងស្លាប់យ៉ាងវេទនានៅសមរភូមិ ប៉ុន្តែមេបញ្ជាការរបស់ពួកគេនឹងត្រូវបានដំឡើងឋានន្តរស័ក្តិ កើបលុយ និងសប្បាយជាមួយស្រីញីទៅវិញ"។

ថ្ងៃទី២៦ ខែសីហា - ម៉ៅ លីនដា អាយុ៣១ឆ្នាំត្រូវបានចាប់ខ្លួនពីបទជេរប្រមាថនិងបរិហារកេរ្តិ៍នៅក្រុងប៉ោយប៉ែតចំពោះការហៅលោក ហ៊ុន សែន ថាជាជនក្បត់ជាតិនៅលើហ្វេសប៊ុក។

ថ្ងៃទី១៥ខែកញ្ញា - មឿង លីហ័រ អាយុ២០ ឆ្នាំជាអ្នកលក់ផ្លែឈើនៅប្រទេសថៃត្រូវបានចាប់ខ្លួននៅក្រុងប៉ោយប៉ែតពីបទញុះញង់ និងជេរប្រមាថជាសាធារណៈជុំវិញការបង្ហោះសារលើទំព័រហ្វេសប៊ុកដែលហៅលោកនាយករដ្ឋមន្ត្រីថាជា "ជនក្បត់ជាតិ" និង "ជាឃាតករ"។

ថ្ងៃទី២៤ខែតុលា - ឈុន សិទ្ធី សមាជិកក្រុមប្រឹក្សាឃុំក្នុងខេត្តប៉ៃលិនត្រូវបានចាប់ខ្លួនពីបទញុះញង់ឱ្យមានការរើសអើងជុំវិញការបង្ហោះវីដេអូក្នុងទំព័រហ្វេសប៊ុក ប្រមាថចោលការអញ្ជើញរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យមន្ត្រីបក្សប្រឆាំងចុះចូល។

"បើប្រៀបធៀបទៅនឹងប្រាំឆ្នាំមុន អ្នកសារព័ត៌មានឥឡូវយល់អំពី [ក្រមសីលធម៌ និងវិជ្ជាជីវៈ] ច្រើន។ ពួកគេបានផ្លាស់ប្តូរច្រើនដោយសារតែមានវគ្គបណ្តុះបណ្តាល និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ រដ្ឋាភិបាល និងនាយកដ្ឋានរបស់ពួកគេក៏បានទប់ស្កាត់[អោកប្បកិរិយាដែលគ្មានក្រមសីលធម៌] ផងដែរ។ វិជ្ជាជីវៈសារព័ត៌មានរបស់ពួកគេគឺ ល្អប្រសើរជាងមុន"

## កាន់តែមានការបណ្តុះបណ្តាល កាន់តែមានការត្រួតពិនិត្យតាមដាន

៨០% នៃអ្នកសារព័ត៌មានកម្ពុជានៅក្នុងការស្ទាបស្ទង់មតិបាននិយាយថា ពួកគេបានចូលរួមវគ្គបណ្តុះបណ្តាលច្រើនជាង៥ដងក្នុងអំឡុងពេលនៃការប្រកបអាជីពរបស់ពួកគេ (សរុប៦០%)។ នៅឆ្នាំ២០១៥ មានតែ ២៨% ប៉ុណ្ណោះបាននិយាយថា ពួកគេបានចូលរួម។ បើយើងតាមការស្ទង់មតិមុនៗ កង្វះខាតការអប់រំ និងការបណ្តុះបណ្តាលត្រូវបានលើកឡើងថាជាបញ្ហាប្រឈមដ៏ធំសម្រាប់វិស័យប្រព័ន្ធផ្សព្វផ្សាយ។

លោក ហ៊ុយ វណ្ណៈ ប្រធានសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជាដែលទើបបានបង្កើតឡើងនៅខែសីហាឆ្នាំ២០១៦ បាននិយាយថា រហូតមកទល់ពេលនេះ សហភាពរបស់លោកបានរៀបចំវគ្គបណ្តុះបណ្តាលដែលមានរយៈពេលច្រើនថ្ងៃចំនួនពីរលើករួចមកហើយដោយក្នុងនោះមានសិក្ខាកាមចូលរួមសរុបជាង២០០នាក់។

លោក ហ៊ុយ វណ្ណៈដែលជាអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាប្រធានផ្នែកព័ត៌មាននៃបណ្តាញទូរទស្សន៍កម្ពុជា (CTN) បានមានប្រសាសន៍ថា ប្រធានបទសំខាន់ៗចំនួនប្រាំនៅក្នុងវគ្គបណ្តុះបណ្តាលទាំងនោះគឺការសរសេរព័ត៌មាន ការសម្ភាស ការងារព័ត៌មានច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយ និងតួនាទីអ្នកនាំពាក្យ។

លោកបានថ្លែងថា "យើងប្រាប់ពួកគេដោយស្មោះត្រង់បំផុត...។ ប្រសិនបើអ្នកជាស្ថាប័នផ្សព្វផ្សាយឯកជន អ្នកត្រូវធ្វើឱ្យមានតុល្យភាពហើយស្តាប់ថៅហ្វាយនាយរបស់អ្នក និងនិពន្ធនាយករបស់អ្នក។ ពួកគេនឹងអនុញ្ញាតឱ្យអ្នកនៅបន្តការងារទៀត"។

លោក ហ៊ុយ វណ្ណៈ បាននិយាយថា គោលបំណងគឺដើម្បីលើកកម្ពស់វិជ្ជាជីវៈសារព័ត៌មានក្នុងចំណោមអ្នកសារព័ត៌មាននៅក្នុងប្រទេស និងផ្តល់ជូនព័ត៌មានដែលគុណភាពជាជាងការរាយការណ៍ធម្មតាៗ។ ដោយផ្អែកលើមតិយោបល់របស់អ្នកជំនាញ លោកបានថ្លែងថា "អ្នកត្រូវតែកសាងសមត្ថភាពរបស់អ្នកដើម្បីសម្រេចថាអ្វីទៅជាហេតុការណ៍ពិត ហើយទៅឱ្យហួសពីនេះ និងពន្យល់ពីមូលហេតុដែលហេតុការណ៍នេះបានកើតឡើង ហើយនឹងមានអ្វីកើតឡើង"។

លោក ហ៊ុយ វណ្ណៈ បានបន្ថែមថា សមាជិកសហភាពជាង១.០០០នាក់ត្រូវបានធ្វើបច្ចុប្បន្នភាព ហើយត្រូវបានផ្តល់ដំបូន្មានណែនាំតាមរយៈបណ្តាញសង្គមតេឡេក្រាម ឬ Telegram ។

លោកបាននិយាយថា"ខ្ញុំបានចែករំលែកពីទិសដៅខ្លឹមសារព័ត៌មាន តើខ្លឹមសារអ្វីដែលល្អ អ្វីដែលគួរយកជាមូលដ្ឋានសម្រាប់អត្ថបទព័ត៌មាននៅពេលនេះ តើអ្វីទៅដែលប្រសើរសម្រាប់យើងក្នុងការផ្តល់ព័ត៌មាន

ប្រសិនបើយើងខ្វះសារៈសំខាន់ ឬធ្វើរឿងនយោបាយច្រើនពេក វានឹងធ្វើឱ្យប្រជាពលរដ្ឋមានការលំបាកខ្លាំង"។

លោក ហ៊ុយ វណ្ណៈបាននិយាយទៀតថា ឧស្សាហកម្មនេះក៏ត្រូវការច្បាប់ច្បាស់លាស់ដែរ ហើយលោកបានបន្តថា លោកសូមកោតសរសើរពីរបៀបដែលប្រទេសសិង្ហបុរីគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយរបស់គេ។ (ប្រទេសសិង្ហបុរី បច្ចុប្បន្នស្ថិតនៅលំដាប់ថ្នាក់ទាបជាងប្រទេសកម្ពុជាលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អ្នកសារព័ត៌មានគ្មានព្រំដែន។ អ្នកសារព័ត៌មានគ្មានព្រំដែនកត់សម្គាល់ឃើញថា អាជ្ញាធរអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសសិង្ហបុរី "មានអំណាចធ្វើការត្រួតពិនិត្យខ្លឹមសារសារព័ត៌មានទាំងក្នុងប្រព័ន្ធផ្សព្វផ្សាយតាមបែបមិនទាន់សម័យនិងតាមអ៊ីនធឺណិត")។

ជាងបីភាគបួននៃអ្នកសារព័ត៌មានដែលបានស្ទាបស្ទង់មតិបាននិយាយថា ពួកគេបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់កម្រិតសាកលវិទ្យាល័យនៅក្នុងវិស័យជាច្រើន ដោយពួកគេភាគច្រើនរៀនវិជ្ជាជីវៈសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយជាចម្បង ចំណែកឯភាសាអង់គ្លេស និងច្បាប់ជាមុខវិជ្ជាបន្ទាប់បន្សំ។

ការបណ្តុះបណ្តាលដែលមានអត្ថប្រយោជន៍បំផុត




*មិនបានជំរុញ

## កង្វះវិជ្ជាជីវៈ

៨៥% នៃអ្នកដែលបានផ្តល់បទសម្ភាសន៍បាននិយាយថាពួកគេមិនគិតថា ភាគច្រើននៃអ្នកសារព័ត៌មានបានអនុវត្តវិជ្ជាជីវៈគ្រប់គ្រាន់ដោយខ្លួនឯងឡើយ ដែលកើនឡើងពី ៤៤% នៅឆ្នាំ២០១៥។ អ្នកផ្តល់បទសម្ភាសន៍ជាច្រើនបាននិយាយថា ស្ថានភាពកំពុងតែប្រសើរឡើង ប៉ុន្តែការទទួលសំណូកនៅតែមានជាទូទៅដដែល។

អ្នកផ្តល់បទសម្ភាសន៍ម្នាក់បាននិយាយថា "ពួកគេបានព្យាយាម។ ពួកគេបានរីកចម្រើនច្រើន។ ពួកគេមានចំណេះដឹង ប៉ុន្តែពេលខ្លះពួកគេបិទភ្នែកដើម្បីទទួលបានប្រាក់ចំណូលបន្ថែម។ វាជាបញ្ហាដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះសារព័ត៌មាន។

២៥% បាននិយាយថា ប្រាក់ខែទាបគឺជាឫសគល់

កត្តាសំខាន់បំផុតដែលរួមចំណែកដល់អាកប្បកិរិយាដែលគ្មានក្រមសីលធម




### អ្នកគំរាមទារប្រាក់

ជារឿយៗគេរាយការណ៍ថា អ្នកសារព័ត៌មាននិងក្រុមអ្នកគំរាមទារប្រាក់ក្លែងបន្លំធ្វើជាអ្នកយកព័ត៌មានបានស្វែងរកការសូកប៉ាន់ពីអ្នកជួញដូរឈើខុសច្បាប់ជាថ្នូរនឹងការមិនចុះផ្សាយអត្ថបទនិងរូបថត។ ក្នុងករណីជាច្រើនស្ថាប័នប្រព័ន្ធផ្សព្វផ្សាយដែលក្រុមអ្នកសារព័ត៌មានក្លែងក្លាយទាំងនោះអះអាងថាពួកគេកំពុងបម្រើការងារឱ្យនោះគឺមិនមានជារូបរាងឡើយ ឬពេលខ្លះវាគ្រាន់តែជាប្លក់អនឡាញមួយដែលគេស្ទើរតែមិនដែលធ្វើបច្ចុប្បន្នភាពទាល់តែសោះ។

អ្នកយកព័ត៌មានប្រចាំខេត្តម្នាក់បាននិយាយថា ទោះជាយ៉ាងណាក៏ដោយសេណារីយ៉ូនេះកំពុងត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីគំរាមកំហែងអ្នកសារព័ត៌មានស្របច្បាប់។

លោកបានថ្លែងថា "ឈ្មួញខុសច្បាប់តែងតែឃុបឃិតជាមួយមន្ត្រីដែលមានអំណាចនិងអាជ្ញាធរពាក់ព័ន្ធដើម្បីដាក់អន្ទាក់ចាប់អ្នកយកព័ត៌មានដែលគំរាមទារប្រាក់។ នេះគឺជាបញ្ហាប្រឈមដ៏ធំបំផុត។ នៅពេលមានការគំរាមកំហែងអ្នកយកព័ត៌មានរបស់យើងភាគច្រើនមិនហ៊ានរាយការណ៍ទេ ព្រោះពួកគេបារម្ភអំពីការសងសឹក និងត្រូវគេចាប់ដាក់ពន្ធនាគារ"។

កាលពីខែមិថុនា អ្នកសារព័ត៌មានប្រចាំខេត្តចំនួនប្រហែល៥០ នាក់បាន

តើអ្នកសារព័ត៌មានភាគច្រើនធ្វើដោយមានវិជ្ជាជីវៈគ្រប់គ្រាន់ឬទេ?



បាទ/ចាស 10%  មិនដឹង 5%  ទេ 85%

នៃអាកប្បកិរិយាប្រាសចាកក្រមសីលធម៌។ "អ្វីដែលសំខាន់នោះគឺថាមនុស្សត្រូវការរស់។ ប្រសិនបើពួកគេមានប្រាក់ខែគ្រប់គ្រាន់ ពួកគេនឹងធ្វើអ្វីៗគ្រប់យ៉ាងសមស្របតាមវិជ្ជាជីវៈមិនខាន"។

ទោះបីជាយ៉ាងណាក៏ដោយ ការចែករំលែកធំបំផុតមួយដែលផ្តល់ជូនដោយអ្នកផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា ៤៣% ឯកភាពថា វប្បធម៌នៃអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាគឺជាមូលហេតុចម្បងនៃអាកប្បកិរិយាដែលគ្មានក្រមសីលធម៌។ នេះគឺជាការដកស្រង់ចេញពីការស្ទង់មតិមុនដែលបានលើកឡើងថាប្រាក់ខែទាបគឺជាបុព្វហេតុឈានមុខគេ ហើយអាចបង្ហាញថា ការខ្វះវិជ្ជាជីវៈបានរាលដាលចាប់ពីការអនុវត្តការទទួលសំណូករហូតដល់ការរាយការណ៍មានភាពលម្អៀងនិងការរាយការណ៍ដោយធ្វេសប្រហែលផងដែរ។

អ្នកសារព័ត៌មានម្នាក់បាននិយាយថា "ស្ថានីយទូរទស្សន៍ទាំងអស់ត្រូវបានបង្កើតឡើងដោយអ្នកមានអំណាច និងមន្ត្រីរដ្ឋាភិបាល។ អ្នកសារព័ត៌មានមិនអាចធ្វើការងារតាមវិជ្ជាជីវៈបានទេ។ ពួកគេអាចរាយការណ៍តែពីរឿងណាដែលល្អរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ"។

ជួបជុំគ្នានៅទីស្តីការក្រសួងព័ត៌មាននៅរាជធានីភ្នំពេញដើម្បីតវ៉ានឹងការចាប់ខ្លួនអ្នកសារព័ត៌មាន៤នាក់នៅក្នុងខេត្តរតនគិរីពីបទគំរាមទារប្រាក់។អ្នកសារព័ត៌មានដែលបានចុះទៅទីនោះបាននិយាយថា អាជ្ញាធរបានព្យាយាមបំភិតបំភ័យអ្នកយកព័ត៌មានដោយចោទប្រកាន់ពួកគេពីការគំរាមទារប្រាក់ ហើយពួកគេបរាជ័យក្នុងការចាប់ខ្លួនអ្នកជួញដូរឈើ ខណៈដែលអាជ្ញាធរនិយាយថា អ្នកសារព័ត៌មានទាំង៤ នាក់បានគំរាមទារប្រាក់ដើមចោទច្រើនឆ្នាំមកហើយ។

ករណីស្រដៀងគ្នាពីរផ្សេងទៀតត្រូវបានរាយការណ៍នៅឆ្នាំ២០១៧៖

នៅថ្ងៃទី០៩ ខែមិថុនា អ្នកសារព័ត៌មាន៣នាក់ត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់កសិករម្នាក់ថាបានកេងប្រវ័ញ្ចយកដីរដ្ឋដោយខុសច្បាប់ក្នុងខេត្តកំពង់ធំ ហើយបានទាមទារប្រាក់ចំនួន៨០០ ដុល្លារជាថ្នូរនឹងការនៅស្ងាត់ស្ងៀម។

យោងតាមមន្ត្រីមូលដ្ឋានម្នាក់បានឱ្យដឹងថា នៅថ្ងៃទី០១ ខែកុម្ភៈ អ្នកសារព័ត៌មាន៧ នាក់ត្រូវអ្នកភូមិនៅខេត្តរតនគិរីព្រួតវាយដោយចោទប្រកាន់ថា បានគំរាមទារប្រាក់ពួកគាត់ចំពោះការ"ដឹកឈើបន្តិចបន្តួចដើម្បីលក់ដូរផ្គត់ផ្គង់គ្រួសារនិងចិញ្ចឹមជីវិត"។

## និន្នាការបន្ថែមទៀត

### ការទទួលបានព័ត៌មាន

អ្នកសារព័ត៌មានបានវាយតម្លៃថាកំរិត ឬ ស្ថានភាពដែលពួកគេអាចទទួលបានព័ត៌មានផ្សេងៗពីរដ្ឋាភិបាលស្ថិតនៅចន្លោះពីកំរិត "ដែលអាចទទួលបានដោយការខំប្រឹងប្រែង" និង "ការទទួលបានដោយការលំបាក"។ ព័ត៌មានមួយចំនួនដូចជា ឯកសារតុលាការ កំណត់ត្រានៃការលក់ដីធ្លី និងបញ្ជីឈ្មោះបុគ្គលិកសាធារណៈជាដើម ត្រូវបានចាត់ទុកថាជាព័ត៌មានដែលទទួលបានដោយការលំបាកបំផុត។ ចំណែកឯតម្លៃសេវាសាធារណៈ និងកំណត់ត្រារបស់រដ្ឋសភាត្រូវបានចាត់ទុកថាជាព័ត៌មានដែលអាចទទួលបានដោយងាយស្រួលបំផុត។

ខណៈដែលក្រសួងព័ត៌មាន និងអង្គការយូណេស្កូបន្តធ្វើការលើច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននោះ អ្នកសារព័ត៌មានមួយចំនួនមានក្តីសង្ឃឹមថា ច្បាប់នេះនឹងធ្វើឱ្យមានការខ្វែងគំនិតគ្នាខ្លះ។ ៦៥% មានមន្ទិលថាច្បាប់នេះនឹងមិនធ្វើឱ្យស្ថានភាពនៃការទទួលបានព័ត៌មានរបស់ក្រុមអ្នកសារព័ត៌មានភាពប្រសើរឡើងនោះឡើយ ក្នុងខណៈដែល៣១% ដែលគិតថាវានឹងអាចធ្វើឱ្យប្រសើរឡើងជាងមុន។

### លក្ខខណ្ឌការងារ

៣៩% នៃអ្នកដែលបានផ្តល់បទសម្ភាសន៍និយាយថា ពួកគេមានការពេញចិត្ត ឬពេញចិត្តខ្លាំងចំពោះការងាររបស់ពួកគេសម្រាប់ពិន្ទុ៣,៤ ក្នុងចំណោម៥។ និន្នាការនេះបង្ហាញពីការពេញចិត្តតិចតួច ទោះបីវាធ្លាក់ចុះយ៉ាងខ្លាំងពីឆ្នាំ២០១៥ ដែលនៅពេលនោះ ៨០% បាននិយាយថាពួកគេពេញចិត្តនឹងការងាររបស់ពួកគេ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺអ្នកសារព័តមានដែលបានស្ទាបស្ទង់មតិមិនសូវពេញចិត្តនឹងសមាសធាតុជាក់ស្តែងនៃការងាររបស់ពួកគេប៉ុន្មានទេ ដូចជាកំរិតប្រាក់ខែ អត្ថប្រយោជន៍ផ្សេងៗ ម៉ោងធ្វើការ កម្រិតស្រេ្តស និងសុវត្ថិភាពជាជាងអ្វីៗផ្សេងទៀតដែលពួកគេមានជាទូទៅ។ ពួកគេមិនសូវពេញចិត្តនឹងកម្រិតស្រេ្តសរបស់ពួកគេនៅកម្រិត២,៨ក្នុងចំណោម៥ និងពេញចិត្តបំផុតជាមួយម៉ោងធ្វើការរបស់ពួកគេនៅកម្រិត៣,៣។

### យេនឌ័រ

ជាមធ្យម អ្នកសារព័ត៌មានស្រីដែលបានស្ទាបស្ទង់មតិមានអាយុនៅក្មេងនិងមិនសូវមានបទពិសោធន៍ដោយជាមធ្យមពួកគេមានអាយុប្រហែល៣០ឆ្នាំនិងមានបទពិសោធន៍៧ឆ្នាំ បើធៀបទៅនឹងបុរសមានអាយុ៣៩ឆ្នាំ និងមានបទពិសោធន៍១២ឆ្នាំ។ ពួកគេទំនងជាបានឆ្លងកាត់ការវាយប្រហារក្នុងអំឡុងពេលនៃការប្រកបអាជីពរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែភាគរយនៃការទទួលរងការគំរាមកំហែងគឺមានតែ៣៥% តិចជាងបើធៀបទៅនឹងបុរសគឺ៥៧%។

កង្វះការយល់ដឹងផ្នែកយេនឌ័រតាមស្ថាប័នប្រព័ន្ធផ្សព្វផ្សាយនានានៅប្រទេសកម្ពុជាបានបង្កឱ្យមានភាពចម្រូងចម្រាសនៅឆ្នាំនេះ ជាពិសេសនៅពេលដែលលោក មាស ឫទ្ធី អ្នកអានព័ត៌មានដ៏មានប្រជាប្រិយមួយរូបប្រចាំទូរទស្សន៍ហង្សមាសបានលើកឡើងអំពីករណីរំលោភហើយសម្លាប់នៅពេលកំពុងផ្សាយតាមកញ្ចក់ទូរទស្សន៍ក្នុងខែសីហា និងបានណែនាំជនចាប់រំលោភកុំឱ្យសម្លាប់ជនរងគ្រោះធ្វើអ្វី ដោយលោកលើកឡើងថា "ហេតុអ្វីមិនទុកប្រើប្រាស់ថ្ងៃក្រោយទៀត?"។ បញ្ហានេះបាននាំឱ្យមានការដាក់ញត្តិតាមប្រព័ន្ធអ៊ីនធឺណិត

និងទាមទារឱ្យសុំទោសតាមកញ្ចក់ទូរទស្សន៍។ កាលពីខែកក្កដា ក្រសួងព័ត៌មាននិងក្រសួងកិច្ចការនារីបានចុះហត្ថលេខាលើក្រមសីលធម៌ថ្មីមួយដើម្បីរាយការណ៍អំពីអំពើហិង្សាមកលើស្ត្រី ដោយជំរុញឱ្យប្រព័ន្ធផ្សព្វផ្សាយនានាចៀសវាងការស្តីបន្ទោសជនរងគ្រោះរួមនឹងគោលការណ៍ណែនាំផ្សេងៗមួយចំនួនទៀត។

### បញ្ហាប្រឈមធំបំផុត

សរុបមក បន្ទាប់ពីឆ្នាំដ៏ច្របូកច្របល់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ អ្នកដែលបានផ្តល់បទសម្ភាសន៍បាននិយាយថាឥទ្ធិពលរបស់រដ្ឋាភិបាលគឺជាបញ្ហាដ៏ធំបំផុតដែលអ្នកសារព័ត៌មានប្រឈមមុខសព្វថ្ងៃ។ ៤៩% បាននិយាយថា ការគ្រប់គ្រងនិងឥទ្ធិពលរបស់រដ្ឋាភិបាលគឺជាបញ្ហាដ៏ធំបំផុត ហើយ ១៨% និយាយថាវាជាការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែងផ្លូវច្បាប់ទៅលើអ្នកសារព័ត៌មាន។

បើទោះជាអ្នកសារព័ត៌មានបានរិះគន់យ៉ាងខ្លាំងចំពោះការគំរាមកំហែង និងការគាបសង្កត់កាន់តែខ្លាំងឡើងលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក៏ដោយក៏អ្នកផ្តល់បទសម្ភាសន៍ម្នាក់បាននិយាយថា ស្ថានភាពនេះអាចកាន់តែអាក្រក់ទៅៗ។ "ថ្វីបើមានការដាក់កំហិតថ្មីបំផុតលើប្រព័ន្ធផ្សព្វផ្សាយមួយចំនួនក៏ដោយ  ក៏ប្រជាពលរដ្ឋនៅតែមានលទ្ធភាពទទួលបានព័ត៌មានល្អដែរ។គេនៅតែអាចស្តាប់ ឬ អានខ្លឹមសារព័ត៌មានរបស់វិទ្យុអាស៊ីសេរី វីអូអេ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតបានដដែល"។

### ការលំបាកក្នុងការទទួលបានព័ត៌មាន

| | → MORE DIFFICULT |
|---|---|
| របាយការណ៍ការលក់ដី/សម្បទានដី | 2.9/4 |
| សេចក្តីសម្រេច/ឯកសាររបស់តុលាការ | 2.8 |
| បញ្ជីឈ្មោះបុគ្គលិកសាធារណៈ | 2.8 |
| ថវិកាជាតិ/មូលដ្ឋាន | 2.6 |
| ប្រាក់ខែមន្ត្រីសាធារណៈ | 2.5 |
| សេចក្តីព្រាងច្បាប | 2.4 |
| របាយការណ៍របស់រដ្ឋសភា | 2.1 |
| តម្លៃសេវាសាធារណៈ | 2.0 |

### ការរាយការណ៍ពីភាពលំបាក

| | → MORE DIFFICULT |
|---|---|
| អំពើពុករលួយ | 4.2/5 |
| សម្បទានដី | 3.7 |
| បញ្ហាព្រំដែន | 3.5 |
| តុលាការ | 3.4 |
| នយោបាយ/អ្នកនយោបាយ | 3.4 |
| សិទ្ធិមនុស្ស | 3.3 |
| ច្បាប់/គោលនយោបាយ | 3.1 |
| បរិស្ថាន | 3.0 |
| ការតវ៉ា | 2.8 |
| បទឧក្រិដ្ឋ | 2.6 |
| បញ្ហាប្រព័ន្ធផ្សព្វផ្សាយ | 2.4 |
| កិច្ចព្រមព្រៀងពាណិជ្ជកម្ម | 2.4 |
| សុខភាព | 2.0 |
| សាសនា | 1.9 |
| ការអប់រំ | 1.9 |

### បញ្ហាប្រឈមធំបំផុត

| | |
|---|---|
| ការគ្រប់គ្រង/ឥទ្ធិពលរបស់រដ្ឋាភិបាល | 49% |
| ការចោទប្រកាន់និងការគំរាមកំហែងផ្នែកច្បាប | 18% |
| ប្រាក់ខែទាប | 8% |
| ខ្វះជំនាញ ឬការអប់រំ | 7% |
| សេរីភាពសារព័ត៌មានលើបណ្តាញអ៊ីនធឺណិតដែលបានដាក់កម្រិត | 7% |
| ខ្វះលទ្ធភាពទទួលបានព័ត៌មាន | 6% |
| កង្វះភាពសត្យានុម័ត/ភាពលម្អៀងលើបុគ្គល | 3% |
| ការអនុវត្តប្រាសចាកក្រមសីលធម៌ដោយអ្នកសារព័ត៌មាន | 3% |

# អនុសាសន៍

"មានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យកាន់តែតិច អ្នកមានអំណាចកាន់តែមានសេរីភាព ដែលធ្វើសកម្មភាពដោយគ្មាននិទណ្ឌភាព។ វាជាស្ថានភាពអាក្រក់សម្រាប់មនុស្សគ្រប់គ្នានៅក្នុងប្រទេសដែលកាន់តែធ្លាក់ចុះដុនដាប ក៏ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែដឹងនោះទេ"

"សេរីភាពពិតនៃប្រព័ន្ធផ្សព្វផ្សាយមានន័យថា មានទាំងអ្នកសរសើរ និងអ្នករិះគន់"

ដោយផ្អែកលើការអភិវឌ្ឍនៅក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយកម្ពុជាអំឡុងឆ្នាំ ២០១៧ និងទិន្នន័យដែលប្រមូលបានពីការស្ទង់មតិអំពីអាកប្បកិរិយានិងការយល់ឃើញរបស់អ្នកសារព័ត៌មានវិជ្ជាជីវៈ CCIM បានធ្វើអនុសាសន៍ដូចខាងក្រោមដើម្បីបង្កើនឯករាជភាព និងវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយកម្ពុជា៖

## ប្រព័ន្ធផ្សព្វផ្សាយ

1. ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយគួរតែប្តេជ្ញាផ្តល់នូវការគាំទ្រទាំងអស់ដែលចាំបាច់ចំពោះអ្នកយកព័ត៌មានទាំងអស់ក្នុងករណីមានភាពអាសន្នទាក់ទងទៅនឹងការងាររបស់ពួកគេ។ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយទាំងអស់គួរតែបង្កើតគោលនយោបាយ និងផែនការសន្តិសុខដោយចែងលម្អិតអំពីនីតិវិធីគ្រាអាសន្នព្រមទាំងប្រភេទនៃជំនួយដែលពួកគេនឹងផ្តល់ជូនដល់បុគ្គលិករបស់ខ្លួន រួមមានការតំណាងផ្នែកច្បាប់ ការព្យាបាលវេជ្ជសាស្ត្រ និងការតាំងទីលំនៅថ្មីបណ្តោះអាសន្នទៅកាន់កន្លែងសុវត្ថិភាពជាដើម។ យ៉ាងហោចណាស់ ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវផ្តល់បេឡាជាតិរបបសន្តិសុខសង្គម ឬសំណងពេលគ្រោះថ្នាក់ដល់បុគ្គលិករបស់ខ្លួនដែលតម្រូវដោយច្បាប់ ហើយគួរពិចារណាផ្តល់ការធានារ៉ាប់រងសុខភាពផង។

2. សមាគមអ្នកសារព័ត៌មានគួរធ្វើការដោយឯករាជ្យនិងដោយគ្មានរបៀបវារៈនយោបាយដើម្បីការពារអ្នកកាសែតនិងលើកកម្ពស់វិជ្ជាជីវៈសារព័ត៌មានអាជីព និងសេរីភាពសារព័ត៌មាន។

## សង្គមស៊ីវិល

1. ធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយដើម្បីលើកកម្ពស់សុវត្ថិភាព និងការការពារអ្នកសារព័ត៌មានដោយផ្តល់ជូននូវវគ្គសិក្សាផ្នែកសន្តិសុខរាងកាយ និងប្រព័ន្ធឌីជីថល។

2. ផ្តល់អាទិភាពលើការកសាងសមត្ថភាពអ្នកសារព័ត៌មានជាមធ្យោបាយមួយក្នុងការបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងសេរីភាពក្នុងការបញ្ចេញមតិរបស់ពលរដ្ឋ។ ជាពិសេសផ្តោតទៅលើវិស័យនានាដែលអ្នកសារព័ត៌មានកំណត់ថាជាអាទិភាព រួមមានរបាយការណ៍ស៊ើបអង្កេតនិងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន។

3. ម្ចាស់ជំនួយអន្តរជាតិគួរបន្តគាំទ្រការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា។

## រដ្ឋាភិបាល

1. បង្កើតស្ថាប័នដែលមានលក្ខណៈឯករាជ្យពីនយោបាយក្នុងការទទួលខុសត្រូវលើការចេញអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ។ ត្រូវធានាឱ្យមានតម្លាភាពក្នុងដំណើរការផ្តល់អាជ្ញាប័ណ្ណដើម្បីអោយរលកធាតុអាកាសសាធារណៈត្រូវបានគេបើកចំហចំពោះគ្រប់សំឡេង ការបញ្ចេញមតិយោបល់ និងព័ត៌មានឯករាជ្យ។ ធានាឱ្យមានតម្លាភាពក្នុងការផ្តល់អាជ្ញាប័ណ្ណនិងការចុះបញ្ជីប្រព័ន្ធផ្សព្វផ្សាយ និងការចេញប័ណ្ណព័ត៌មានដល់អ្នកសារព័ត៌មាន។

2. ពន្លឿនពង្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដោយសហការជាមួយសង្គមស៊ីវិលនិងប្រកាន់ខ្ជាប់នូវគោលការណ៍នៃការទទួលបានព័ត៌មាន រួមទាំងជំនួបដោយចំហនិងការទទួលបានព័ត៌មានដោយស្មើភាពសម្រាប់អ្នកសារព័ត៌មានមកពីគ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់។

3. ការធ្វើវិសោធនកម្មច្បាប់ស្តីពីសារព័ត៌មានគួរតែធ្វើឡើងដោយស្វែងរកមតិយោបល់ពីអ្នកពាក់ព័ន្ធឱ្យបានច្រើន រួមមានសង្គមស៊ីវិលនិងសមាគមសារព័ត៌មាន និងសិក្សាការអនុវត្តល្អៗកំរិតអន្តរជាតិដើម្បីលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងការការពារអ្នកសារព័ត៌មាន។

4. ការចោទប្រកាន់ពីសកម្មភាពចារកម្មមិនគួរត្រូវបានប្រើដើម្បីដាក់ទោសលើអ្នកសារព័តមានដែលកំពុងបម្រើការងារនោះឡើយ។

5. បន្ថយការដាក់សម្ពាធដែលមានកាន់តែខ្លាំងឡើងលើអ្នកសារព័ត៌មាននិង ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ  និងបង្កើនការប្តេជ្ញាការពារសេរីភាពសារព័ត៌មាននៅកម្ពុជាឡើងវិញ។